00787936

E180

សិក្ខាកថា

# មេរៀនដកស្រង់ពីពិសោធន៍

# នៃ

# ចាស់ទុំជំនាន់មុន


ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 12 / 03 / 2012
ម៉ោង (Time/Heure) : 11h25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA




កាំង ហ្គេកអ៊ាវ

កាំង ហ្គេកអ៊ាវ
2012

00787937

ពាក្យពេចន៍ដំបូង

អត្ថបទ តទៅនេះ បង្ក្រងឡើងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលបានជួបប្រទះ បានដឹងឮ បានស្រាវជ្រាវ – ហើយវិភាគ និងសរុប ក្នុងគោលបំណងបំរើឧត្តមគតិ បង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ។

សង្ឃឹម ទទួលបាន កិច្ចសហការ យ៉ាងទូលំទូលាយ និងជ្រាលជ្រៅ។

យើងទាំងអស់គ្នា រស់ដើម្បីជាតិសុខដុម។

អ្នកសិក្សាស្វែងយល់ម្នាក់



កាំង ហ្គេកអ៊ាវ

00787938

E180

## លំនាំដើម

ឆ្នាំ1863 អាណានិគមនិយមបារាំងចូលស្រុកខ្មែរ ក្រោមរូបភាពអាណាព្យាបាល។

ចលនាប្រដាប់អាវុធវាយបារាំង បានផុសឡើងជាក្រុមឯករាជតំបន់ - ច្រើនក្រុម។ ក្រុមស្មើរតែទាំងអស់ ដឹកនាំដោយអចិត ពីព្រោះជំនាន់នោះ លោកសង្ឃជាអ្នកបានរៀនសូត្រ ចេះដឹងជាងគេ សឹកមកជាអចិត ក៏នៅជាប់ជិតស្និទ្ធនឹងមហាជន ទាំងពេលស្រួល ទាំងពេលលំបាក ម្ល៉ោះហើយ ទើបមហាជនជឿទុកចិត្ត។ 1

ឆ្នាំ1945 មានចលនាតស៊ូ ផុសឡើងម្តងទៀត។ ចលនាលើកនេះ ខុសប្លែកគ្នា ដូចតទៅ៖

• ពួកតស៊ូ៖ ស្មើរតែទាំងអស់ ជាពួករាជានិយម
• តស៊ូ៖ សឺង ង៉ុកថាញ់ មាននិន្នាការអាមេរិក
• តស៊ូ៖ សឺង ង៉ុកមិញ ជាចលនាកុម្មុយនីស។

ចន្លោះពីឆ្នាំ1949 ដល់ឆ្នាំ1953 បារាំងបានប្រគល់ស្វ័យភាពដល់ខេត្តកំពង់ធំ សៀមរាប បន្ទាប់មកដល់ខេត្តបាត់ដំបង។ តស៊ូរាជានិយម នៅក្នុងខេត្តទាំងនេះ បានថ្វាយអំណាចចំពោះព្រះមហាក្សត្រ។

ឆ្នាំ1953 ថ្ងៃ9វិច្ឆិកា បារាំងប្រគល់ឯករាជ្យ ឲ្យព្រះរាជាណាចក្រកម្ពុជា ថ្វាយព្រះមហាក្សត្រខ្មែរ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន។

តស៊ូ៖ សឺង ង៉ុកមិញ គឺបក្សប្រជាជនបដិវត្តកម្ពុជា បានពន្យល់ដូច្នេះថា៖ "ឯករាជ្យ ដែលបារាំងប្រគល់ឲ្យខ្មែរ ជាឧបាយកលយកស្លឹកត្នោតរុំស្ករត្នោត"។ នេះមកពីវៀតណាម ត្រូវការខ្មែរ រួមចំណែកបន្តសង្គ្រាមឥណ្ឌូចិន។

ឆ្នាំ1954 កងទ័ពបារាំង បរាជ័យនៅធៀនបៀនភូ សង្គ្រាមឥណ្ឌូចិនត្រូវបានបញ្ចប់ សន្និសីទហ្ស៊ឺណែវក៏ចាប់ផ្តើម។

ថ្ងៃ20កក្កដា1954 ហ្ស៊ឺណែវសំរេច៖

• ឲ្យបក្សប្រជាជនបដិវត្តកម្ពុជា រំលាយបក្ស រំលាយកងទ័ព រំលាយតំបន់រំដោះ ចូលទៅរស់នៅក្នុងសង្គមជាតិវិញ
• ឲ្យបង្កើតគណៈកម្មការអន្តរជាតិ ការងារត្រួតត្រា ដែលមានសមាសភាព



កាំង ហ្គេកអ៊ាវ

ប្រទេសលោកសេរី និងប្រទេសកុម្មុយនីស តាមខាងសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង។

សង្កេត៖ សេចក្តីសំរេចរបស់ហ្សឺណែវ ជាគោលការណ៍បង្រួបបង្រួមជាតិខ្មែរ ឲ្យស្ថិត នៅក្រោមឧបុលកាជានិយម។

ក្នុងការអនុវត្ត កិច្ចព្រមព្រៀងនេះ ហូជីមិញបានសំរេច៖

• ដកសឺនង៉ុកមិញ ឲ្យទៅនៅហាណូយ ទុកស៊ីវហេងឲ្យទទួលខុសត្រូវក្នុងប្រទេស។

• ដកយុទ្ធជនវៀតកុម្មុយនីស្តខ្មែរ 1700 នាក់ យកទៅរៀននៅវៀតណាម។

ក្នុងការអនុវត្ត កិច្ចព្រមព្រៀងនេះដែរ បក្សប្រជាជនបដិវត្តកម្ពុជា តាមគំនិតផ្តើមរបស់ ប៉ុល ពត បានសំរេចបំបែកកម្លាំងជាបី៖

មួយ.– កម្លាំងចំហ សំរាប់ឈរឈ្មោះបោះឆ្នោត ហៅថា "ក្រុមប្រជាជន"។

ពីរ.– កម្លាំងសម្ងាត់ គឺប៉ុលពត និងថ្នាក់ដឹកនាំបក្ស។

បី.– កម្លាំងពាក់កណ្តាលចំហ គឺកុម្មុយនីស្តមួយចំនួន ដែលប៉ុលពតចាត់តាំងឲ្យទៅនៅក្នុង គណៈបក្សប្រជាធិបតេយ្យ។.

ឆ្នាំ 1954 ថ្ងៃ 8 កញ្ញា សន្ធិសញ្ញាម៉ានីលបង្កើត SEATO ដែលជាសម្ពន្ធភាពការពារ។

ឆ្នាំ 1955 ថ្ងៃ 24 មេសា សន្និសីទបានឌុង បានអនុម័ត គោលការណ៍សន្តិភាព 5 ខ។

ឆ្នាំ 1955 ថ្ងៃ 15 ឧសភា ព្រះមហាក្សត្រខ្មែរ បានចេញសេចក្តីថ្លែងការណ៍មួយ ដាក់ប្រទេសកម្ពុជា ឲ្យនៅជាប្រទេសប្រកាន់យកនយោបាយអព្យាក្រឹត មិនស្ថិតនៅក្រោម ការការពារ ដោយឆ័ត្ររបស់ SEATO ទេ។

ព្រះអង្គទ្រង់បាន ប្រកាសដាក់រាជសម្បត្តិ ផងដែរ។

សភាពការណ៍សន្តិសុខ ក្នុងប្រទេស នៅពេលនោះមានដូចតទៅ៖

មួយ.– គស្យុះ សឺន ង៉ុកមិញ ត្រូវបានដោះស្រាយ តាមសេចក្តីសំរេចរបស់ហ្សឺណែវ។ គស្យុះ សឺន ង៉ុកថាញ់–ខ្មែរសេរី–ត្រូវបានបើកចេញពីជងដែក ទៅជ្រក នៅភាគខាងត្បូងវៀតណាម។

ពីរ.– ពួកចោរព្រៃ ដែលចាប់មនុស្សជំរិតយកលុយ ត្រូវបានបង្ក្រាប។

ពីថ្ងៃ 9 វិច្ឆិកា 1953 មកដល់ថ្ងៃ 15 ឧសភា 1955 មានរយៈពេល 1 ឆ្នាំ 6 ខែ 6 ថ្ងៃ សុបិនចាស់ៗ ដំរាន់មុខ ចាប់តាំងតែពីសម័យក្រឡាហោមគង់ ត្រូវបានវែរម្ចាក់ធ្វើឲ្យបានសំរេច គឺធ្វើឲ្យកម្ពុជា ដែលទើបបានឯករាជ្យ ត្រូវបានបង្រួបបង្រួមជាតិ មានសន្តិសុខ មានសន្តិភាព ចាប់ផ្តើម សេចមុខ សេចមាត់ មានអព្យាក្រឹតភាព លើឆាកអន្តរជាតិ។ បញ្ហានេះ មិនធម្មតា ប៉ុន្មានទេ ពីព្រោះត្រូវឆ្លងកាត់ព្យុះកំណាច SEATO ។

ខ្មែរយើងជំនាន់នេះ និងជំនាន់តៗទៅ ទទួលស្គាល់ថាខ្លួនមានកាតព្វកិច្ចសិក្សាស្វែង



គាំង ហ្គេកអ៊ាវ

យល់ នូវមូលហេតុ បរាជ័យ និងជ័យជំនះ នៃមនុស្សជំនាន់មុន ។

សង្កេត៖ នៅចិន តឹង សៀវភីង បានប្រើពេលវេលា 20ឆ្នាំចុងក្រោយនៃជីវិតគាត់ ចងក្រងពិសោធន៍ បើកទិសការណ៍ថ្មី ទុកជាកេរដំណែល ឲ្យកូនចៅជំនាន់ក្រោយ ។ ក្មេងៗ ជំនាន់នេះ ដែលមានជោគជ័យ គេមានមោទនភាពស្រលាញ់ជ្រៅណាស់ នឹងអ្នកចាស់ទុំ "តឹង" របស់ គេ ។

លន់ណុល និង ប៉ុលពត សុទ្ធតែជួបបរាជ័យ យ៉ាងជូរចត់បំផុតក្នុងជីវិត ទោះបី ចែកឋានទៅហើយ ក៏នៅតែកគោលគំនិតអ្វី ទុកឲ្យកូនចៅជំនាន់ក្រោយ ភ្លឺស្វាងផង មិនបាន ។

រឿង លន់ណុល ជារឿងស្ថិតនៅក្រោមយុត្តាធិការ អាមេរិក តែគាត់ ក៏ជាអ្នកចាស់ទុំម្នាក់របស់ខ្មែរ ។

រឿង ប៉ុលពត នួន ជា អ៊ុងជឿន ជារឿងស្ថិតនៅក្នុងយុត្តាធិការ អាមេរិក ក្នុងនេះ មាននួនជាម្នាក់ដែរ ដែលនៅរស់ តែគាត់មិនទាន់បានធ្វើ ឲ្យគេឯងមានសង្ឃឹមសោះនៅឡើយ ។

13

កាំង ហ្គេកអ៊ាវ

## ជំពូកមួយ

## សង្ខេបប្រវត្តិកម្ពុជា តាមការស្រាវជ្រាវផ្ទាល់

1

### I.- មានសន្តិភាព មានសន្តិសុខ ទើបមានការរីកចំរើន

#### ក.- ការរីកចំរើនក្នុងប្រទេស

គឺសំដៅការរីកចំរើន ក្នុងការកសាងធនធានមនុស្ស តាមរយៈពង្រីកសិក្សាធិការ និងកសាងឧស្សាហកម្មស្រាល។

15ឆ្នាំ ពីឆ្នាំ1955 ដល់1970 សិក្សាធិការរីកចំរើនលឿនណាស់។ ចលនាកសាងធនធានមនុស្ស ជាអ្នកផលិត និងបញ្ញាជន ក៏មានសន្ទុះទៅតាមនោះដែរ។

ឧស្សាហកម្មស្រាល ជាផ្នែកកសាងកម្មករឧស្សាហកម្ម។ គ្រាន់តែរោងចក្រតម្បាញកំពង់ចាមមួយ មានកម្មករ 600ក្លួយនាក់។ ទូទាំងប្រទេស អាចមានកម្មករ ពី6ពាន់ទៅមួយម៉ឺននាក់ ដែលកំពុងតែរំក្លប់មុខជំនាញជារៀងរាល់ថ្ងៃ។ ទន្ទឹមគ្នា នឹងកំណើតកម្មករ ក៏មានកំណើតនាយទុនជាតិ។ កម្មករ ឧស្សាហកម្ម និងនាយទុនជាតិ ជាធនធានមនុស្ស។

#### ខ.- ការរីកចំរើន លើឆាកអន្តរជាតិ

ក្រោយសន្និសីទបាណ្ឌុង ដែលប្រទេសអព្យាក្រឹតប្រាំរូប គឺ នេហរូ ទីតូ ស៊ូកាណូ ណាស់សេ និងសីហនុ បានប្រឹងប្រែងពង្រឹងហើយ ពង្រីកជួរប្រទេសអព្យាក្រឹត ហេតុបានក្លាយទៅជាចលនាមិនចូលបក្សសម្ព័ន្ធ។ ចលនាមិនចូលបក្សសម្ព័ន្ធជាបណ្តុំនៃប្រទេស ខ្សត់ផង ខ្សោយផង តែមានគ្នាច្រើន តម្រង់ឲ្យប្រទេសលោកសេរី និងប្រទេសកុម្មុយនីស យកចិត្តទុកដាក់។

ប្រជាជនប្រទេសជាច្រើន ស្គាល់សីហនុ មុនស្គាល់អង្គរវត្ត។

### II.- ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងមហោតមរដ្ឋ

#### ក.- ផ្នត់គំនិតនយោបាយរបស់ប្រជាជនកម្ពុជា

កាំង ហ្គេកអ៊ាវ

00787942

សង្គមកម្ពុជា មានវណ្ណៈ 5 ។ កសិករមានចំនួនលើសពី 85% ។ កសិករកម្ពុជា ជាមនុស្ស សីហនុនិយម និងជួនណាតនិយម ។ គ្មាននរណាអាចប៉ះពាល់តណ្ហាដែនកំពូល គំនិតអម្ចាស់នេះ ដោយកសិករខ្មែរ មិនប្រឆាំងតបនោះទេ ។

ខ.– អំពីចលនាផលិតកម្ម នៅទសវត្សឆ្នាំ 50 និង 60

ក្នុងចលនាផលិតកម្មមួយ ភាគីដែលចូលរួម សុទ្ធតែត្រូវការគ្នាទៅវិញទៅមក តែម្នាក់ៗ មិនស្កប់ចិត្តនឹងកម្រៃ ដែលទទួលបាននោះទេ ។

ឪពុកខ្ញុំ ជាស្មៀននៅក្នុងក្រុមហ៊ុនឡានខ្សែផ្លូវលេខ 6 ។ ឪពុកខ្ញុំ ត្រូវការក្រុមហ៊ុន ដើម្បីរស់ ក្រុមហ៊ុនត្រូវការ ឪពុកខ្ញុំ ដើម្បីការងាររបស់គេ ។ ឪពុកខ្ញុំ ចង់បានកម្រៃថែម តែក្រុមហ៊ុន គេឲ្យខ្លះអត់ខ្លះ ។

ក្រៅពីថៅកែ និងស្មៀន ក្រុមហ៊ុននេះ នៅមានកម្មករ និងអ្នកប្រវាស់ ។ ថៅកែ គឺជាម្ចាស់ហ៊ុនម្នាក់ ដែលចុះទៅជាប់ការងារ ។ ថៅកែ គឺជានាយទុនជាតិ ។ អ្នកប្រវាស់ គឺកសិករ ដែលនៅភូមិជាមួយថៅកែ នៅពេលដែលរួចពីធ្វើស្រែ ក៏ប្រញាប់ចុះទៅចាប់ស៊ី ។

ក្រុមហ៊ុននេះ មាន 10 ហ៊ុន មួយហ៊ុន 10 ម៉ឺនរៀល ។ ថៅកែចូលបានតែបីហ៊ុនកន្លះទេ ។ 6 ហ៊ុនស្ថិតនៅក្នុងកណ្ដាប់ដៃ កូនក្មួយរបស់ឧត្តមមន្ត្រីផុតលេខម្នាក់ ។ ក្រុមហ៊ុននេះចំណាយ 10 ម៉ឺនរៀលរាល់ឆ្នាំ សំរាប់ឲ្យទឹកតែ នៅពេលដែល ចេញថ្លៃឡូត៍ ។

កម្មកររបស់ក្រុមហ៊ុននេះ បានប្រាក់ខែ 300៛ ស្មៀនបាន 1 500៛ ថៅកែបាន 3 000៛ គិតអស់ថ្លៃ ហូបបាយក្រុមហ៊ុន ។ ថៅកែនិងស្មៀន មកការហូតព្រឹកមួយកូនកែវ ហើយក៏ចាប់ផ្ដើមការងារ មុនដល់ពេលបាយ ។ ក្រុមហ៊ុននេះធ្វើការតែ 6 ខែក្នុងរដូវនេសាទ ។ មួយហ៊ុន ចំណេញបាន 10 ម៉ឺនរៀល ។

សង្កេត៖ នៅឆ្នាំ 1965 កម្មករសំណង់ ដែលគេហៅថាគូលីអាទិត្យ បានឈ្នួលឯង បានមួយថ្ងៃ 20៛ ។ ដំណាច់នោះ អង្ករ មួយគីឡូ 2,5៛ សាច់ជ្រូកមួយគីឡូ 20 ទៅ 25៛ គុយទាវមួយចាន 10៛ មាសមួយតម្លឹង 3 300៛ កង់ Peugeot មួយ 7 500៛ ។

គ.– ស្វែងយល់អំពីមនោគមវិជ្ជា នៅទសវត្សឆ្នាំ 50 និង 60

នាយទុនជាតិ មិនមែនជាសត្រូវស្លាប់រស់ របស់វណ្ណៈកម្មករទេ តែជាមនុស្សឈ្លាសវៃ ក្នុងការងារ ។ តែនសម្បត្តិ កុលាបប៉ៃលិន – នាយទុនអគ្គបទអក្សរសិល្ប៍ – ជាមនុស្សភ្លឺស្វាង ក្នុងក្នុងមុខរបរ និងក្នុងការជ្រើសរើសអ្នកបន្តវេន ប៉ុន្តែ បែរជាត្រូវបានបទអត្ថាធិប្បាយអក្សរសិល្ប៍ ទសវត្សឆ្នាំ 60 លាបពណ៌ខ្មៅឲ្យ តាមគោលគំនិតខ្សែភាគរបស់សហភាពសូវៀត ។

ឥណកសិកម្ម "បណ្ដាក់" ជាបន្ទុកដ៏ធ្ងន់ ដែលធ្លាក់ទៅលើកសិករក្រ ប៉ុន្តែតម្លៃ ហេតុមួយ ដែលប៉ុល ពត លើកឡើង ក្នុងសុន្ទរកថា ថ្ងៃ 27 កញ្ញា 1977 ជាតម្លៃបំផ្លើស ។

វណ្ណៈណាក៏ដោយ ក៏មិនត្រូវលើក ឬទម្លាក់ឲ្យខុសពីការពិត ។ មុនឆ្នាំ 1970 បក្សកុម្មុយនីស្តកម្ពុជា បានលាបពណ៌ខ្មៅយ៉ាងកាចសាហាវ ប៉ះពាល់ដល់វណ្ណៈជាច្រើន ។ ក្រោយ 17 មេសា ក៏លេចចេញការសំលាប់រង្គាល យ៉ាងកាចសាហាវ គួរឲ្យខ្លាច ។

5



កាំង ហេកអ៊ាវ

មុនឆ្នាំ1970 បក្សបានពន្យល់ ដល់បេសកជនថា វណ្ណៈសក្តិភូមិកាន់អំណាច អនុវត្តនយោបាយ ទុកតែភាវូបនីយកម្ម ពោលអាណានិគមភាវូបនីយកម្ម និងហ្វាស៊ីស្តភាវូបនីយកម្ម។ ក្រោយ17មេសា ទើបលេចចេញការពិត។ ខ្លឹមសារ ដែលពន្យល់នេះ ជាយុទ្ធវិធីផ្តួលរំលំសីហនុ តាមផែនការមួយថ្នាក់ៗ (កំណត់ 166 ERN 00 078 015 និង 693 ERN 00 003 140_141)។

បញ្ជាក់៖ មុនឆ្នាំ1970 បក្សប្រើពាក្យ វណ្ណៈសក្តិភូមិកាន់អំណាច ជំនួសពាក្យសីហនុ។

III.– អំពីលន់ណុល និងប៉ុលពត

៦

ក.– លន់ណុល

លន់ ណុល ជាសិស្សច្បងនៃសិស្សសាលាទាហានសកម្ម ជំនាន់ទីមួយ។ គាត់មានជំនឿលើអាវុធទំនើប សង្គ្រាមសម័យថ្មី និងជឿវេទមន្ត។ គាត់មានមហិច្ឆតានយោបាយមួយ យ៉ាងធ្ងន់ធ្ងរ គឺកសាងរបបសាធារណរដ្ឋ បែបប្រជាធិបតេយ្យ។ គាត់បដិសេធបង្រួបបង្រួមជាតិ។ ទិសដែលគាត់កំណត់ គឺ លើកជាតិនិយម ដោយរដ្ឋប្រហារ កំទេចកុម្មុយនិស្ត ដោយសង្គ្រាមសម័យថ្មី។

លន់ ណុល ជាមនុស្សសាសនា។ បណ្ណាល័យគាត់ធំ សៀវភៅដែលគាត់មានច្រើនប៉ុន្មាន គាត់អានទាំងអស់។ សៀវភៅ "ដំណើរខ្មែរ" ដែលគាត់និពន្ធ មិនសូវមានមនុស្សចាប់អារម្មណ៍។

លន់ ណុល យកចិត្តទុកដាក់ប្រមូលតែ កម្លាំងប្រដាប់អាវុធ និងកម្លាំងស្រទាប់លើ ដែលជាទាហាន តម្រួត ចៅក្រម សភា អភិបាល និងចៅហ្វាយខេត្តគ្រប់ខេត្ត ដើម្បីយកកម្លាំងនេះ ទៅក្តោបយកអំណាច តាមបែបក្រពើក្រញ៉ាក់ចំណី។

លន់ ណុល មិនគិតគូរ កសិករ ទាល់តែសោះ។ គាត់មិនយល់ថា ឧត្តមគតិនយោបាយ ទោះបីល្អយ៉ាងណាក៏ដោយ ក៏ត្រូវឲ្យកម្លាំងជាតិ ជាពិសេសគឺកសិករ ដែលមានចំនួន លើសពី85% យល់ស្រុះស្រួលសិន ទើបកម្លាំងនេះ គាំទ្រគាត់។

ខ.– ប៉ុល ពត

ប៉ុល ពត ជាកុម្មុយនីស្តស្ទើរឯកោ។

ចាប់តាំងតែពីឆ្នាំ1968 ដែលគាត់មានឱកាសផ្លាស់ប្តូរយោបល់ ជាមួយ ខាងសឹង មេគំនិតម្នាក់ នៃបដិវត្តវប្បធម៌ គាត់តាំងខ្លួនជាអ្នកស្នងត្រកូលនៃចលនាបដិវត្តអធន អន្តរជាតិ។ គាត់កំណត់សត្រូវយុទ្ធសាស្ត្រច្រើនណាស់ គឺចក្រពត្តិ អាណានិគម សេរីនិយម រិវិស៊ីនិយម សហព័ន្ធឥណ្ឌូចិន បរិវារចក្រពត្តិ សក្តិភូមិ នាយទុន អនុទុន។

ជាយុទ្ធវិធី ប៉ុលពត ណែនាំឲ្យបែងចែកច្បាស់លាស់ណាស់ រវាងចំហ និងសម្ងាត់ អ្វីមិនត្រូវនិយាយ កុំនិយាយ អ្វីដែលត្រូវនិយាយ ក៏ត្រូវចេះសំភាល។ គាត់ណែនាំឲ្យ ចេះបត់បែន តាមស្ថានភាពការណ៍ជាក់ស្តែង ដូចជា លើកទង់ការពារអាត្មាក្រិត្យ ជាដើម។



កាំង ហ្គេកអាវ

00787944

ទិសរបស់ ប៉ុល ពត គឺកសាងកម្លាំងបដិវត្តន៍នៅជនបទ យកជនបទឡោមព័ទ្ធទីក្រុង រំដោះប្រទេសជាតិ តាមរយៈសង្គ្រាមប្រជាជន។

ចំពោះ សង្គ្រាម ប៉ុលពតជាអគ្គបញ្ញាការមានសមត្ថភាព។ ឯកសារ "សង្គ្រាមប្រជាជន" "យុទ្ធវិធីសង្គ្រាមឈ្លប" "គោលនយោបាយមួយចំនួនរបស់បក្ស" ដែលប៉ុលពតនិពន្ធ ឆ្លើយស្របនឹងសេចក្ដីត្រូវការចាំបាច់។

ប៉ុល ពត ជាមនុស្សហ្មត់ចត់ ចំពោះការងារ ពេលបើកសមាជម្ដងៗ ដែនទី នៅជាប់នឹងខ្លួន។

គ.- សរុបមក

លន់ណុល ស៊ីន ផ៉ុកថាប់ ម្ខាង ប៉ុលពត នួនជា អ៊ុងហ៊ឿន ម្ខាងទៀត សុទ្ធតែយកសង្គ្រាម ជាមធ្យោបាយ វាយផ្ដាច់ភាគីប្រឆាំង។

## IV.- ក្រោយហ្សឺណែវ ការងារដំបូងៗរបស់បក្ស

ដំបូង បក្សភ្ជាប់ខ្សែការងារឲ្យកម្មាភិបាលឡើងវិញ។

ឆ្នាំ1956 បក្សចាត់តាំង"កងការពារសម្ងាត់" គឺចាត់តាំងមនុស្សរបស់បក្ស ទៅធ្វើជីវពលឃុំ កាន់កាំភ្លើងឃុំ ការពារកម្មាភិបាល នៅពេលធ្វើដំណើរ។

បញ្ជាក់ៈ កម្មាភិបាលមជ្ឈិមបក្ស មានមធ្យោបាយការពារខ្លួនផ្សេងទៀតច្រើន។ ក្នុងនេះ លុយជាមធ្យោបាយសំខាន់បំផុត ពេលឃុំចេញ គេបាំ លុយ ដែលសុទ្ធតែជាក្រដាស 100រ ពីសំពៀតខ្លួនម្នាក់ៗ។

ឆ្នាំ1958 បក្សចាប់ផ្ដើមកសាងកងឈ្លប។

ចំពោះការងារប្រជាជន បក្សបានចាប់ផ្ដើម ដោយចាត់តាំងអង្គការចំហ សំរាប់បិទបាំង សកម្មភាពពាក់កណ្ដាលចំហ។ សមាគមឆ្លងទន្លេ សមាគមចេច សមាគមស្ត្រី ក្រុមប្រវាស់ដៃ ជាអង្គការស្របច្បាប់ ចំហ ដែលកម្មាភិបាលថ្មី ម្នាក់ៗ ម៉ែទាត់ រៀនចាត់តាំង រៀនឃោសនាអប់រំ រៀនចាត់ចែងសកម្មភាពចំហ។ តំរង់នេះ គឺធ្វើឲ្យភ្ជាប់មនោសញ្ចេតនា ជាមួយប្រជាជន។ សកម្មភាពពាក់កណ្ដាចំហ គឺឃោសនាមាត់ទេ អំពីជិវិត ក្នុងស្រុក អំពីបដិវត្តន៍។ ចុងបញ្ចប់ ចាត់តាំងក្រុមរៀនសូត្រ ឯកសារចំរែ។

បញ្ជាក់ៈ សមាគមស្ត្រី និងក្រុមប្រវាស់ដៃ ជាពន្លកនៃសហករណ៍។

ប៉ុលពត ដណ្ដើមកម្លាំងកសិករ តាំងពីហូរ តាមយុទ្ធវិធីចិញ្ចាំប្របិច ម្ដងបានមួយៗ ប៉ុន្តែរដ្ឋប្រហារ ថ្ងៃ18 មិនា1970 បានធ្វើឲ្យប៉ុលពត មានកម្លាំងធំ។

## V.- ប៉ុលពត និងថ្នាក់ដឹកនាំបក្សប្រជាជនបដិវត្តន៍កម្ពុជា មុន17មេសា1975

កាំង ហេកអ៊ាវ

កម្មាភិបាលចំហពីរនាក់ គឺណុប បូផាន់ និងខួន ស្ទួន ត្រូវហ៊ុំងសម្លាប់និងជាប់ដាក់គុក។

កម្មាភិបាលសម្ងាត់ ដែលមានតួនាទីដឹកនាំបក្ស ត្រូវបានប៉ុលពត កៀសចេញ ផ្ដើលដើង និងកំទេចអស់8នាក់៖

1.– ស៊ីវ ហេង ត្រូវបានកៀសចេញ នៅឆ្នាំ 1960។

2.– ទូ សាមុត ត្រូវបានកំទេច នៅថ្ងៃ 20 កក្កដា 1962។

3.– ប៉ែន យុត ត្រូវបានសរសេរក្នុងឯកសារថា ជាជនក្បត់– បាត់ដំណឹង។

4.– ស៊ីចួន ហៅ ម៉ុន– ប៉ុលពតសរសេរថាក្បត់ តែលោកមិនទុកឲ្យ។

5.– យ៉ុង ត្រូវបាន ប៉ុល ពត បញ្ជាឲ្យក្រុមយួនកំទេច។

៨ 6.– ម៉ីម៉ង់ ត្រូវបានកំទេច នៅឆ្នាំ 1968 នៅលើកំពូលវិភាល់។

7.– កែវ មាស ត្រូវបានផ្ដើលដើងចោល នៅព្រះវិហារ នៅឆ្នាំ 1973។

8.– ប្រសិទ្ធ ហៅចុង អនុលេខាធិការ ត្រូវបានកំទេច នៅឆ្នាំ 1974។

កម្មាភិបាលមធ្យម ដែលមានអាយុបក្ស ពី8ឆ្នាំឡើងទៅ ត្រូវបានបក្សបោះបង់ចោល ពីព្រោះក្នុងលក្ខន្តិកៈ ឆ្នាំ1960 ចែងថា៖ "សមមិត្តរូបណា ដែលមានអាយុបក្ស 10 ឆ្នាំឡើង បក្សនឹងពិចារ្យលើភាពមជ្ឈិមជូន"។ សិង្គន កំពង់សិលា តោឈុំ ព្រែក ប្រសិទ្ធ សុទ្ធតែចង់ភ្ជាប់ ខ្សែបក្សឡើងវិញ តែបក្សមិនភ្ជាប់ឲ្យ។

លក្ខន្តិកៈបក្ស ឆ្នាំ 1971 បោះបង់លក្ខខណ្ឌអតីតភាពចោល យក "លក្ខណៈសម្បត្តិ 10យ៉ាង" ជំនួសវិញ (D00674 ERN 00 053 020 – 023) គឺដើម្បីបំណងកំចាត់កម្មាភិបាលចាស់ៗ ដែលបក្ស មិនចង់ឲ្យចូលមជ្ឈិមនេះឯង។

VI.– សកម្មភាពប្រឆាំងបដិវត្ត និងសកម្មភាពបដិវត្ត ពីឆ្នាំ1956ដល់ឆ្នាំ1966

នៅភ្នំពេញ ក្រោយពេល ដែល SEATO ចាប់កំណើត មានលេចចេញសកម្មភាព របស់ បេសកកម្ម ជំនួយយោធាអាមេរិកាំង និងសកម្មភាពរបស់ ក្មេងទំនើង គឺពួកផ្កាយព្រឹក និងពួក Solex កង់ស។

បន្ទាប់មក មានលេចចេញព្រឹត្តិការណ៍ ដែលអ្នកផង នៅចងចាំបានគឺ៖

–. សម សារី ប៉ែកម៉ុរ តេច្ខ្លួនផុត។

–. ផែនការ រដ្ឋប្រហាររបស់ដាបឈួន បរាជ័យ។

–. ចាប៉ុល ជាម វិញ្ញាតុង ផ្ញើឡុស៊ីកចូលព្រះបរមរាជវាំង_ស្លាប់មហាវ័ង។

–. Bernard LABAT និង សុង សាក់ តំទីដានិត បំផ្លាញថវិកាជាតិ។

–. "ដែប" ចាប៉ុលនៃអ័ន់ ចូលមកអន្ទូត ផែនការដាក់មីន តាមផ្លូវពោធិចិនតុង បំណងធ្វើឃាត សម្ដេចព្រះមហាក្សត្រិយានី និងលីវ សាវណ៍ តែបរាជ័យ។

–. មេទ័ព សៅ មន្ត្រីពាបអ៊ិន ដាចម ត្រូវបានតុលាការសឹក កាត់ទោសប្រហារជីវិត។

បញ្ជាក់៖ ដាម វិញ្ញាតុងនិងដែប ជាប់គុកធំ រហូតដល់ថ្ងៃ 3.4.1970។



កាង ហេកអ៊ាវ

00787946

ឆ្នាំ1963-64 សភាពការណ៍សកលលោក ដើម្បីរំលឹកខ្លះ៖

-. ថ្ងៃ 22 វិច្ឆិកា 1964 KENNEDY ត្រូវបានឃាតករបាញ់សម្លាប់នៅ Dallas។

-. ឆ្នាំ1964 អាមេរិកចូលអន្តរាគមន៍ផ្ទាល់ ក្នុងសង្គ្រាមវៀតណាម។

-. នៅឡាវ មានរដ្ឋប្រហារ របស់ ខុង ឡេ។

-. នៅថៃ សារិត ធាណារ៉ាត់ ស្លាប់។

-. នៅវៀតណាម ឌួង វ៉ាន់ មិញ ធ្វើរដ្ឋប្រហារកំទេចក្រុមគ្រួសារង៉ោ ឌិញ ឌៀម។ បន្ទាប់មក ង្វៀន ខាញ់ ធ្វើរដ្ឋប្រហារទម្លាក់ ឌួង វ៉ាន់ មិញ។

សីហនុ៖ ជងទីស្និតខ្មែរ នៅភ្នំពេញ ពីពាក់ពោះ ហៅព្រឹត្តិការណ៍ទាំងអស់នេះ ថា អាមេរិកាំង ប៉ុនេះ។

នេះជាតម្រុយ ដែលបង្ហាញថា រដ្ឋប្រហារ មានលទ្ធភាពផ្ទុះនៅកម្ពុជា។ 

ខែកញ្ញា ឆ្នាំ1964 បក្សបានប្រមូលកម្លាំងទាំងអស់ ដែលខ្ទេចការបាន បាន ចលាចល ជាទូទៅមួយ ដូចពាក្យមានចលប្រជាជនថា លន់ណុល មានដៃនការ ធ្វើរដ្ឋប្រហារ។ ចលាចលលើកទីមួយនេះ ត្រូវបានប្រជាជនយ៉ាងទូលំទូលាយ ចាប់អារម្មណ៍។ ចលាចលបន្ទាប់មកទៀត ធ្វើជាលក្ខណៈរាយឆ្លក់ - ម្តងប្អូនដប់ថ្លៃស្អែក ត្រង់នេះ ម្តងប្អូនដប់ថ្លៃស្អែកត្រង់នោះ។ នៅជនបទ ក្នុងខេត្តចម្រូត ចលាចល ស្ទើរតែមកណាប់ស្រុង។

បញ្ជាក់៖ បន្ទាប់ពីចលាចលលើកទីមួយ លន់ណុលបានចាប់អ្នកបាច បាន ជាង10នាក់ ដាក់ឃុំឃាំង។ ជនចាំបើនផ្សេងទៀត បានរត់ចូលព្រៃ ជាបន្តបន្ទាប់ ចូលរួមការបដិវត្ត ក្នុងស្មារតី មិនព្រមសម្ងំតទៅទៀត។

## VII.- កម្លាំងលន់ណុល និងកម្លាំងប៉ុលពត មុនពេលរដ្ឋប្រហារ

រដ្ឋសភាទីតិកាល1966-1970 ជាកម្លាំងនយោបាយរបស់លន់ណុល។

រដ្ឋាភិបាលឆ្នាំ1966 របស់លន់ណុល ប្រឈួតប្រជែងក្នុងបរិបទនយោបាយ នៅអាស៊ីអាគ្នេយ៍ កំពុងតែពុះកញ្ជ្រោល សង្គ្រាមនៅវៀតណាម កំពុងតែឡើងខ្លាំង រដ្ឋប្រហារនៅឥណ្ឌូនេស៊ី កំពុងតែកាប់សម្លាប់មនុស្ស។ លន់ណុលសម្រេចរដ្ឋាភិបាលរបស់គាត់ ដោយបើកដៃអនុវត្តដែនការកាន់កាប់ជនបទ ដោយយោធា- បង្ក្រាបកសិករ ដែលតវ៉ា យ៉ាងសាហាវ។

បក្សពួកខ្មែរ ដោយកម្លាំងកងឈ្លប នៅតិច បានសំរេចឲ្យកសិករ និងកម្លាំងបដិវត្ត តេចបូរសឹក។ ខាងសំឡូត កសិករ នាំគ្នាតទល់ទៀតក៏វាយតប។

លន់ណុល ត្រូវបានបង្ខំឲ្យលាលែងរដ្ឋាភិបាលឆ្នាំ1966 តែគាត់បានបន្តការពារក្បាល យ៉ាងឃោរឃៅ យ៉ាងសកម្ម និងពាសពេញ។

ឆ្នាំ1967 បក្សបានយកចិត្តទុកដាក់ ពង្រីកកងឈ្លប។ ចុងឆ្នាំ1967 មានកម្លាំង



តាំង ហុកអាវ

កងឈ្លបទៅគ្រប់ទីតាំងយុទ្ធសាស្ត្រ ល្បួមវាយក្តាប់ជើងទាហានបុន ទើបវាយប៉ុស្តិ៍បាយដំរី នៅថ្ងៃ 18 មករា 1968 បើកវគ្គផ្ដើមសង្គ្រាមប្រជាជន សង្គ្រាមរំដោះជាតិ។

ចុងឆ្នាំ1968 ភូមិភាគឦសាន រំដោះបានទឹកដីទំហំប៉ុនខេត្តកំពង់ឆ្នាំង។

## VIII.– សកម្មភាពរដ្ឋប្រហាររបស់លន់ណុល

ឆ្នាំ1969 ខែកញ្ញា លន់ណុល បង្កើតរដ្ឋាភិបាលរដ្ឋប្រហារ ដោយដាក់ឈ្មោះថា "រដ្ឋាភិបាលស្រោចស្រង់ជាតិ"។ គាត់អនុវត្តផែនការជាជំហានៗដូចតទៅ៖

១២

–. ផ្ដាច់មុខប្រមូលទិញស្រូវគ្រប់ស្រុក តាមយុទ្ធវិធី ក្តាប់ស្បៀង ត្រៀមសង្គ្រាម។

–. ធ្វើឃាតឥស្សរជនមួយចំនួន ដោយឧបាយកល – សម្ដេចព្រះសង្ឃរាជ ជួនណាត ជាកំពូលឥស្សរជន ដែលគេមិនហ៊ានទុក – ក្រៅពីនេះ មានស្រីវ៉ែង សេង ស៊ុនថៃ និងប៉ែនកាបូ។

–. ក្នុងរដ្ឋសភា គេដកកែវសានចេញ ហើយដាក់អ៊ិនតាំឲ្យធ្វើប្រធានរដ្ឋសភាជំនួស។

–. ថ្ងៃ8 មីនា 1970 គេប្រឌិតរឿងទាហានវៀតកុង ឈ្លានពាន ត្រូវទាហានខ្មែរវាយបែកអស់បានអាវុធមួយចំនួន។

–. ថ្ងៃ 13 មីនា 1970 គេធ្វើបាតុកម្មវាយស្ថានទូត សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងស្ថានតំណាងរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន ភាគខាងត្បូងវៀតណាម។

–. ថ្ងៃ 18 មីនា 1970 គេឲ្យទាហានប្រដាប់អាវុធពេញខ្លួន ព័ទ្ធមន្ទីររដ្ឋសភាជាច្រើនជាន់ – គេឲ្យអ៊ិនតាំដឹកនាំប្រជុំសភាតំណាង ដើម្បីដកសេចក្តីទុកចិត្តពីសីហនុ – គេឲ្យច្រើនគ្នា និយាយបើកឆាកមុនគេ។ ចុងបញ្ចប់ អ៊ិនតាំពោលថា "គេក្តាប់អាវុធរួចហើយណា!"។

គេដកសីហនុ ពីឋានៈប្រមុខរដ្ឋ និងពីប្រធានសង្គមរាស្ត្រនិយម គេដាក់ចេង ហេង ជាប្រមុខរដ្ឋ អ៊ិនតាំជាប្រធានសភា និងជាប្រធានសង្គមរាស្ត្រនិយម។

សម្គាល់៖ ក្នុងពេលប្រជុំនោះ មានតែខ្លួនសមាជិកម្នាក់ទេ ដែលមិនហ៊ានប្រមាថសីហនុ ឃុំពោក ក្រៅពីអ្នកផ្សេងទៀតគេតីហកឲ្យ។

## IX.– កម្លាំងលន់ណុល និងកម្លាំងសីហនុ ប៉ុលពត

### ក.– កម្លាំងលន់ណុល

–. កម្លាំងគាំទ្រលន់ណុលតិចណាស់។ មន្ត្រីស្រុកដែលចាំតែទីការលិតមកពីខេត្ត។ មន្ត្រីខេត្ត មន្ត្រីតាមក្រសួង គាំទ្រលន់ណុល មិនអស់ពីពោះទេ ស្ទុយទៅវិញ គេមានក្រោធ និងមួរម៉ៅ យកមកឲ្យលន់ណុល ដោះស្រាយ។

–. ក្រោយពីចាប់ អ៊ុម ម៉ាណូរិន ដាក់ឃុំ សម្ពត ត្រូវបានលន់ណុលបញ្ចាលមកជាទាហាន។ គំនិតទាហាន គាំទ្រសម្ពត ត្រូវបានបំភ្លេចសក្តិ មួយតាម្នាក់ តែក៏នៅតែមាន អ្នកតស៊ូចោលជួរ តម្រូវឲ្យលន់ណុល ចាប់ពីហ៊ានថ្មី។ សាលាបឋមសិក្សា នៅភ្នំពេញ



តាំង ហេកអ៊ាង

00787948

បានក្លាយទៅជាបង្កាយទាហានថ្មី ។

-. នៅក្នុងវេទិកានេះ SEATO បានផ្ដល់អាវុធយុទ្ធភណ្ឌថ្មីឲ្យរដ្ឋាភិបាលសង្គម ដែលគាត់ដឹកជញ្ជូន ទុកដាក់ ចោលអស់ នៅថ្ងៃ 1 មេសា 1970 ។

-. ដើម្បីបោកប្រាស់ភ្លាម គាត់ប្រកាសថា សង្គ្រាមនេះជាសង្គ្រាមដេញវៀតកុង វៀតមិញ "ជាខ្មែរត្រូវតែខ្មែរទៅ" ។ គាត់ឲ្យគេប្រមូលចាប់អាណិកជនវៀតណាម បញ្ជូនទៅស្រុក ។ ដើម្បីទៅវិញ គាត់បើកបែប កក់ទុកដូត ជាបន្ទាន់ ជាមួយសាធារណរដ្ឋវៀតណាម ។ ខែឧសភា ឆ្នាំ 1970 ង៉ៀងវ៉ាន់ធៀវ ចូលមកដល់អ្នកលឿង មកជួយមានមតិបើបចំកន្លែងនេះ ដែលមានសារសំខាន់ ខាងយុទ្ធសាស្ត្រយោធា ។ ង៉ៀងវ៉ាន់ធៀវ ក៏បានឲ្យទាហានគាត់ ចូលស្រុកខ្មែរ តាមពាក្យស្លោក ជួយដេញវៀតកុង តែត្រូវបាន ប្រជាជនកម្ពុជា ជាខូចទៅខ្មោចគោក ពីព្រោះទាហានអស់នេះ បានមកធ្វើឲ្យប៉ះពាល់ ដល់ទ្រព្យសម្បត្តិប្រជាជនកម្ពុជា និងប្រពៃណីស្អាតស្អំរបស់ស្រីខ្មែរ ។ L1

-. ដើម្បីកសាងប្រជាប្រិយភាព របស់គាត់ - ប្រជាប្រិយភាព ដែលគាត់មិនធ្លាប់មាននោះ - នៅថ្ងៃ 3 មេសា 1970 លន់ណុល បានដោះលែងអ្នកទោសនយោបាយទាំងអស់ ។

-. នៅលើឆាកអន្តរជាតិ លន់ណុលទទួល បានការជឿទុកចិត្តពីចំណាស់ ។ ប្រទេសលោកសេរី មានបារាំងជាដើម ទុកត្រឹមតែជាឆៅហ្វ៊ែ - ថៃមួយត្រឹមតែកន្ទេលយក្ស ។

សង្កេតៈ បារាំង និងថៃ ជាប្រទេស 2 ក្នុងចំណោមប្រទេស 8 ដែលបង្កើត SEATO - ព្រលានយន្តហោះ B52 អាមេរិកនៅថៃ - B52 ដែលហោះមកទម្លាក់គ្រាប់បែក លើប្រជាជនកម្ពុជា 200 ថ្ងៃ 200 យប់ គឺហោះចេញពីអ៊ូតាប៉ៅ ។

ខ.- កម្លាំងសីហនុ

កម្លាំងគាំទ្រសីហនុ គឺកសិករ ។ កសិករខ្មែរ គ្មានទ្រព្យសម្បត្តិអ្វីធំដុំទេ តែមានកម្លាំងកាយ កម្លាំងចិត្ត និងជីវិត ដើម្បីសម្ដេចឪរបស់គេ ។

ដូច្នោះ ដែលគាត់ធ្លាប់តែឮ ខ្មែរក្រហមឃោសនា ឥឡូវនេះ គាត់បានឃើញច្បាស់នឹងភ្នែក ហើយ ។ ទទួលលន់ណុល ឲ្យគេជេរប្រមាថសីហនុ យ៉ាងគ្រោតគ្រាត កសិករទាំងតែក្ដៅចិត្ត ក៏ងើបឡើងតវ៉ា ហេតុប៉ះទង្គិចគ្នា ក្លាយជាហិង្សា សម្លាប់ឃោរឃៅ មាត់ថៃ មានតំណាងរាស្ត្រ គឹមផុន ស៊ុះសាម៉ុន និងចៅហ្វាយស្រុក ជីប៊ុនថន ជាដើម ។ ហើយ ក៏នាំគ្នាធ្វើក្បួនចូលមកតវ៉ា នៅភ្នំពេញ តែត្រូវបានលន់ណុលបង្ក្រាប ។ ទាហាន លន់ណុល បាញ់ផ្លោះលើប្រជាជនបាតុករ ស្លាប់អស់ច្រើនណាស់ នៅម្ដុំខាងកើត ក្បាលស្ពាន ជ្រោយចង្វារ ។

គ.- កម្លាំងប៉ុលពត

កងឈ្លបបង្កើត ដែលជាអ្នកវាយឆ្មក់ ទាហានលន់ណុល ចាប់តាំងពីឆ្នាំ 1968 មក ក៏បានសំរុកចេញពីព្រៃ ចុះពីភ្នំ មកវាយដោះ ភូមិស្រុក ដែលជាមូលដ្ឋានបង្អែក ពីមុនមក និងតំបន់ជុំវិញ ព្រមគ្នាបានបោះទីតាំងរដ្ឋអំណាចស្រុក



កាំង ហ្គេកអ៊ាវ

តំបន់ ភូមិភាគ ដែលសុទ្ធតែជាទីតាំងរឹងមាំ មុនថ្ងៃ 17មេសា។

ឃ.- កម្លាំងសីហនុ ប៉ុលពត

យុវជនសីហនុនិយម នៅជនបទ ស្ទើរតែចូលកងទ័ព។ នេះជាវិភាគមក សំរាប់ប៉ុលពត។ ប៉ុលពតប្រមូលផ្តុំកងទ័ព ជាអង្គភាពវរសេនាតូច ចាប់តាំងតែពី ខែ3កក្កដា 1970។ តំបន់នោះ ដែលតភ្ជាប់គ្នាជាផ្ទាំងមួយ នៅលើទឹកដី ទំហំបួន ភាគប្រាំ នៃផ្ទៃប្រទេស ក៏បានបំពេញនាទីជាសមរភូមិក្រោយ ចាប់តាំងតែពីខែកក្កដានោះ មកដែរ។ សមរភូមិក្រោយនេះរឹងប៉ឹង ពីព្រោះមានប្រជាជនច្រើន មានទឹកដីដ៏ទូលាយ
2 មានស្បៀង មានរដ្ឋអំណាច មានកងទ័ព មានបក្សដឹកនាំ។ ទាំងអស់នេះ ស្ថិតនៅក្រោម ការដឹកនាំរបស់ប៉ុលពត ទូនជា។

នៅក្នុងប្រទេស អត្ថភាពរបស់សីហនុ ធ្លាក់ចុះច្រើនណាស់។ វគ្គសិក្សា ឆ្នាំ 1973 និយាយថា៖ "យើងជាអ្នកធ្វើ យើងជាអ្នកហូប ទុកឲ្យសីហនុ គាត់អង្គុយ ធ្វើប្រធាន ឲ្យយើង តែចុះ"។

## X.- ដំណើរវិវត្តនៃសង្គ្រាមប្រជាជន

ឆ្នាំ1973 លន់ណុល ទាមទារចរចាសន្តិភាព។ បន្ទាប់មកអាមេរិក ក៏លើកឡើង អំពីការចរចាផ្ទាល់ ជាមួយនឹងខ្មែរម្ខាងទៀតដែរ។

ប៉ុលពត តែតែពីវាយតទៅទៀត៖
- ថ្ងៃ 1មករា1975 ប៉ុលពតបើកវគ្គ វាយសំរុកផ្តាច់ព្រ័ត្រ។
- ថ្ងៃ 25 មករា 1975 ប៉ុលពតបញ្ចេញមកកាត់កប់អ្នកលឿង
- ថ្ងៃ 1មេសា 1975 លន់ណុលចេញទៅរស់នៅអាមេរិក។
- ថ្ងៃ 12មេសា 1975 ទូតអាមេរិក វិលត្រឡប់ទៅស្រុកវិញ។
- ថ្ងៃ 17 មេសា 1975 ប៉ុលពតចូលដល់ភ្នំពេញ។

ប៉ុលពត ឈ្នះលន់ណុល ដោយសារកត្តាគន្លឹះពីរ គឺ៖
មួយ.- គឺគោលនយោបាយ បង្រួបបង្រួមជាតិរបស់សីហនុ។
ពីរ.- ប៉ុលពត ខ្លួនឯង ជាអគ្គបញ្ជាការ ដែលចេះដឹកនាំសង្គ្រាមប្រជាជន។

ឈ្នះលន់ណុល មិនទាន់បានមួយខួបពេញបរិបូរណ៍ផង ប៉ុលពតធ្វើរដ្ឋប្រហារសីហនុ នៅថ្ងៃ 30 មីនា 1976 (693 ERN 00 003 140-141)។ ពេលនោះ កម្លាំងសីហនុនិយម ស្រទាប់មូលដ្ឋាន ពោលគឺកសិករ បានក្លាយទៅជាកម្លាំងបដិវត្ត អស់ទៅហើយ។

ថ្ងៃ 21 មេសា 1976 ប៉ុលពតសំរេចឲ្យបែងចែក ទូតខ្មែរមកពីបរទេស ពេល


កាំង ហ្គេកអ៊ាវ

00787950

គឺកម្លាំងសីហនុនិយមស្រទាប់លើ ជាប្អូនប្រុសកែ (D00694 ERN 00 019 144)។

## X.– គោលជំហររបស់បក្សចំពោះអនុជន

ឯកសារបក្ស មិនសរសេរឲ្យចំថា "បដិសេធអនុជន" ទេ។ លក្ខន្តិកៈបក្ស ឆ្នាំ 1976 សរសេរថា៖ "ប្រឆាំងបដិវត្តន៍អនុជន" (D00674 ERN 00 053 010)។ បក្សកុម្មុយនិស្តកម្ពុជា ប្លែកពីបក្សផ្សេងទៀតទាំងអស់ ត្រង់បដិសេធអនុជននេះឯង។

សម្គាល់៖ ក្រោយកំណើតសាធារណរដ្ឋប្រជាមានិតចិន 8ឆ្នាំ ម៉ៅ ជីតុង នៅតែបានណែនាំបក្សគាំមូល ក្នុងឯកសារ "អំពីការដោះស្រាយត្រឹមត្រូវទំនាស់ក្នុងផ្ទៃប្រជាជន" ឲ្យប្រកាន់ គោលជំហរ ជាមិត្តមានចំពោះបញ្ញាជន។

នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ជីវិតនយោបាយរបស់ពួកអនុជន ប្រឈមនឹងទិដ្ឋភាពកសិករក្រីក្រយ៉ាងម៉ៅ យ៉ាងស្រួចស្រាវ ដូចសំពាធស្លាប់រស់ ដែលនឹកស្មានមិនដល់។

ចាប់តាំងពីឆ្នាំ 1960 មក មានអនុជនជាច្រើន ដោយជឿថា ធ្វើបដិវត្តន៍ គឺដើម្បីរំដោះប្រជាជន សង្គ្រោះប្រជាជន និងបំរើប្រជាជន បានចូលរួមចលនាតស៊ូនយោបាយ ទាំងចំហ ទាំងសម្ងាត់។ ពួកនេះ ប្រឆាំងនឹងជីវភាព ស្រឡាញ់សន្តិភាព ត្រូវការយុត្តិធម៌ និងចង់កសាងជីវភាពប្រជាជន ដែលក្នុងនោះ មានជីវភាពខ្លួនឯងផងដែរ ឲ្យបានរីកចំរើន។

ឆ្នាំ 1967 បក្សបានជំលៀសអនុជន ដែលតស៊ូបើកមុខ នៅទីក្រុង ឲ្យទៅនៅតំបន់រំដោះ ដើម្បីសុវត្ថិភាព និងរួមចំណែកកសាងមូលដ្ឋានឈ្លប។

ដោយឡែកតែនៅភូមិភាគនិរតី អ៊ុង ជឿន បានអនុវត្តគោលនយោបាយបដិសេធអនុជន ចាប់តាំងពីឆ្នាំ 1967 នោះឯង។ គាត់ថា៖ "ធ្វើស្រែ ស៊ីស្រូវ មើលសៀវភៅស៊ីក្រដាស"។ ម៉ម ង៉ លេខាភូមិភាគ តទល់។ គាត់និយាយថា៖ "កសិករយើង ក្រៀមបានផ្ដូចស្លៅ ចុះលួ តែកន្លែងណា ដែលគោរអាចម៍"។ ឆ្នាំ 1968 ម៉ម ង៉ ត្រូវបាន គេធ្វើឃាត នៅលើកំពូលភ្នំ ខ្ទាល់ តាមរូបភាពពេទ្យទ្រមូច។

នៅឆ្នាំ 1968 នោះដែរ ប៉ុល ពត បានចេញឯកសារ "សីលធម៌បដិវត្ត" ដែលមានខ្លឹមសារ ជាអាទិ៍ថា៖ "នៅកន្លែងណា ត្រូវបំរើប្រជាជនកម្មករ កសិករ នៅកន្លែងនោះឲ្យអស់ពីចិត្ត ពីថ្លើម"។

សម្គាល់៖ "សីលធម៌បដិវត្ត" ត្រូវបាន François PONCHAUD បកប្រែសរសេរចុះក្នុងសៀវភៅ "កម្ពុជាឆ្នាំសូន្យ" ដោយប្រែច្រឡំពាក្យ "កសិកម្ម" ទៅជា "ពលកម្ម" ទៅវិញ។

ចន្លោះពីឆ្នាំ 1968 ដល់ 1971 អ៊ុង ជឿន បានចេញកម្មវិធីបាល 4រូប គឺ វែក ប៉ែន កែ គឹមហួត ជាហួច ជង ម៉ុម ឈឿន ឲ្យចេញពីទំនើ 24ម៉ោង និងបានប្រមូលកម្មវិធីបាលផ្សេងទៀត ទុកចោលមួយកន្លែង។

កាំង ហ្គេកអ៊ាវ

ឆ្នាំ 1971 បក្សបានសំរេច បង្កើតភូមិភាគពិសេស និងបានសំរេចឲ្យប្រមូលមនុស្ស ដែលម៉ុក ជឿន ទុកចោល យកទៅបំពេញការងារមន្ទីរ ជុំវិញមន្ទីរភូមិភាគ។

ឆ្នាំ 1973 "ទង់បដិវត្ត" សរសេរថា៖ "មានវណ្ណៈណា កម្មាភិបាលវណ្ណៈនោះ"។ ពេលនោះ ភូមិភាគនិរតី បានបញ្ចុះឋានៈ កម្មាភិបាលមួយចំនួន។ ឯភូមិភាគពិសេស បក្សបានសំរេច បញ្ជូនកម្មាភិបាលមន្ទីរ ឲ្យទៅលត់ដំ នៅឯដើមទន្លេសាប។

ក្រោយ 17 មេសា 1975 កុយធួន និងអនុផល ដែលកុយធួន បានយកចិត្តទុកដាក់ កសាងប្រែប្រួល ត្រូវបានបក្សប្រមូលចូលភ្នំពេញ យកមកបំបែកតាមក្រសួងនានា។

4 ថ្ងៃ 1 មករា 1977 បក្សចាប់ផ្ដើម សំអាតសំអាង ខ្សែអនុផលរបស់ កុយធួន និងកម្លាំងកសិករកណ្ដាល របស់កែ ពក។

កាលបរិច្ឆេទមិនច្បាស់ ហ៊ូ យន់ ដែលជាបញ្ញាជនល្បីឈ្មោះមួយរូបត្រូវបានកំទេច មកពីគោលជំហរបដិវត្ត មិនកាន់ចលនា។ ហ៊ូ យន់ ទទួលបានត្រឹមតែសហករណ៍កំពតម។ បញ្ញាជនល្បីឈ្មោះផ្សេងទៀត ដូចជា ទៅ សេង ហ៊ូ នឹម ជាដើមត្រូវបានចាប់បញ្ជូនមក ស.21។ អនុផល ថែក ប៉ែន កែ គឹមហួត ជា ហួន និង ម៉ុម ណឿន ជាដើម ក៏ចាប់បញ្ជូនមក ស.21 ដែរ។

គិតមកត្រឹមថ្ងៃ 6 មករា 1979 នៅសល់តែអនុផលបញ្ញាជន 4 រូប គឺ ប៉ុល ពត អៀង សារី សុន សេន ខៀវ សំផន ក្នុងមជ្ឈិមបក្ស។ គ្មានបញ្ញាជនណាម្នាក់បានចូលមជ្ឈិមបក្ស ទៀតទេ។

សង្កេត៖

.មួយ.- បន្ទាប់ពី 17 មេសា មានពាក្យស្លោកយុទ្ធសាស្ត្រ "មហាចលនា មហាជិត មហាលោតផ្លោះ មហាអស្ចារ្យ"។ គឺលោតផ្លោះ ឲ្យដល់កុម្មុយនិស្តនិយម ឲ្យបានឆាប់។

.ពីរ.- នៅឆ្នាំ 1977 ប៉ុល ពត បានលើកទស្សនៈ សភាពការណ៍បដិវត្តអន្តរជាតិ ថា៖ "កន្លងមក គ្មានពិសោធន៍ត្រឹមត្រូវ ក្នុងការថែរក្សារដ្ឋអំណាច" ទេ។

ក្រោយ 7 មករា 1979

• ឆ្នាំ 1983 ប៉ុល ពត ប្រកាសរំលាយ បក្សកុម្មុយនិស្តកម្ពុជា និងប្រកាសចូលនិវត្តន៍ ដោយប្រគល់តួនាទីដឹកនាំ ឲ្យ សុន សេន។ ប៉ុន្តែ អំណាចពិតប្រាកដ នៅតែស្ថិតនៅក្នុងកណ្ដាប់ដៃ ប៉ុល ពត នួន ជា ម៉ុក ជឿន ដដែល។

• ឆ្នាំ 1983 វគ្គសិក្សាបានពន្យល់ថា៖ "សង្គមនិយម និងកុម្មុយនិស្តនិយម មិនមែនជាវត្ថុបំណងទេ — គឺជាមធ្យោបាយកសាងប្រទេស។

សង្កេត៖ ពន្យល់នេះ ផ្ទុយពីសម្ភារៈនិយមប្រវត្តិសាស្ត្រ ទាំងស្រុង។

ឆ្នាំ 1989-90 ប៉ុល ពត បានផ្ដើតវិការ បើកវគ្គកសាងកម្មាភិបាលសេដ្ឋកិច្ច។ នៅពេលនោះ មានលេចចេញទ្រឹស្ដី ប្លែកៗជាច្រើន ដូចជា៖

-. កសិករ គឺសក្តិភូមិ — វាយលើកសិករ គឺវាយលើសក្តិភូមិ។

កាំង ហ្គេកអ៊ាវ

—.ក្រ មិនមែនជាលក្ខណសម្បត្តិ ជុំញ ឲ្យមនុស្ស គោរពបូជាទេ ។
—.ស្រទាប់កណ្ដាល អាចក្រៅគោលដៅជាបក្សការ កាំងអងសេដ្ឋកិច្ច កាំងអង នយោបាយ ។
តាមទ្រឹស្ដី ដែលបង្រៀននេះ សភាពការណ៍ក្ដៅណាស់តែវៀតទៅស្លាប់ ។

ជាក់ស្ដែង គឺផ្ទុយពីសេចក្ដីសង្ឃឹមស្រឡះ ៖
—.ឆ្នាំ 1994 ប៉ុលពត ចាក់ សុនសេន ចេញពីចលនា ។
—.ឆ្នាំ 1997 ប៉ុលពត កំទេចសុនសេន និងគ្រួសារ ។
—.ឆ្នាំ 1997 អ៊ុងហ៊ឿន ធ្វើប្រហារ ប៉ុលពត ដោយប្រើពាក្យស្លោក ដើម្បីការពារបុព្វហេតុ សុនសេន ។
—.ឆ្នាំ 1998 ប៉ុលពត ស្លាប់ ។

បរាជ័យ របស់ប៉ុលពត ក្នុងកណ្ដាប់ដៃ អ៊ុងហ៊ឿន គឺមកពីប៉ុលពត ។
គ្រប់តែពេលការ ជាយុទ្ធវិធីដែលធ្លាប់ប្រើ គាត់ក្ដាប់យកតែកម្លាំង ដែលគាត់ ហៅថា កម្លាំង សាច់ថ្មី - ដំរុះដំងកំទេចចោល កម្លាំងដែលមិនសាច់ថ្មី ។ ចុងបញ្ចប់ នៅសល់តែ ប៉ុលពត ម្នាក់ឯង កណ្ដាលចំងកសិកក្រីក្រដំណម ។

XII.— វៀតណាមកម្ពុជា សម័យខ្សែយន៍ ប៉ុលពត

ក.— បន្ទាប់ពីរដ្ឋប្រហារបស់លន់ណុល
ក្រោយ 18 មីនា 1970 លន់ណុល ចាប់អាណាកដេច វៀតណាមបញ្ជូនទៅស្រុក។ កងទ័ពវៀតណាម ដែលជ្រកអាស្រ័យនៅកម្ពុជា បានវាយសំរុកអំណាច លន់ណុល តាមស្រុក ហើយកសាងរដ្ឋអំណាចថ្មី ។
រដ្ឋអំណាចថ្មីនេះ ជារបស់បក្សពលករវៀតណាម តែមានរូបភាពជាខ្មែរ ៖
—.គណៈកម្មាធិការបក្សតំបន់ បក្សស្រុក សុទ្ធតែជាកម្មាភិបាលវៀតណាម ដែលប្ដូរឈ្មោះជាខ្មែរ ។
—.គណៈកម្មាធិការរណសិរ្ស តំបន់ ស្រុក ឃុំ ភូមិ សុទ្ធតែជាខ្មែរ ។
—.កងទ័ពខ្មែរ ដែលវៀតណាមកសាងបាន ជារបស់បក្សវៀតណាម គ្រប់គ្រងដោយគណៈកម្មាធិការ អនុសេនាធំវៀតណាម ។
—.យុទ្ធភណ្ឌ ជ័យភណ្ឌ ដែលប្រមូលយកបាន ជារបស់បក្សវៀតណាម ។
—.លុយកាក់ ពន្ធដារ ជាកម្មសិទ្ធរបស់បក្សវៀតណាម ។
រដ្ឋអំណាចថ្មីនេះ ជារដ្ឋអំណាចបណ្ដោះអាសន្ន ពេលណាដែលអង្គការខ្មែរ ទៅដល់ ត្រូវប្រគល់មកអង្គការខ្មែរ ៖
មួយ.— ត្រូវប្រគល់ កងទ័ពខ្មែរទាំងអស់ ដែលវៀតណាមកសាងបាន រួមទាំង

កាំង ហេកអ៊ាវ

អាវុធយុទ្ធភ័ណ្ឌ ដែលអង្គភាពនេះ កំពុងកាន់កាប់ប្រើប្រាស់។

ពីរ.– ត្រូវប្រគល់ គណៈកម្មាធិការរណសិរ្ស គ្រប់ជាន់ថ្នាក់ និងបុគ្គលិកខ្មែរ ដែលវៀតណាម ប្រើប្រាស់ ដោយគ្មានអម លក្ខខណ្ឌ អោយខ្មែរ ចាត់តាំងបក្ស និងរដ្ឋ–បាល។

ការប្រគល់ទទួលជាក់ស្តែង មានលក្ខណៈដូចខាងក្រោម៖

• នៅលើទឹកដីណាដែលក្រុម វៀតណាមប្រគល់ ក្នុងខែកក្កដា ឆ្នាំ1970។

• នៅលើទឹកដីខ្លះ សិប្បូ សុយកាក់ពន្ធដារ វៀតណាមក្រញាំ យូរណាស់–មកហើយកាំភ្លើងច្រើន។ ខាងស្ពាន កោះធំ លើកដែក ក្បែរស្វាយ ពន្យាហេតុផលខ្មែរ។

6

## ខ.– តួនាទីនៃតំបន់រំដោះកម្ពុជា

ចាប់តាំងតែ ពីខែកក្កដា 1970មក បក្សកុម្មុយនីស្តកម្ពុជា ជាម្ចាស់តំបន់រំដោះ ព្រមទាំងបានរៀបចំ តំបន់រំដោះនេះ ឲ្យទៅជាសមរភូមិក្រោយ ដែលបំរើចលនាប្រយុទ្ធ នៅកម្ពុជា និងនៅភាគខាងត្បូង វៀតណាម តាមគោលការណ៍អន្តរជាតិនិយមអធន៖

–. កម្ពុជាផ្តល់ជម្រក ស្នាក់អាស្រ័យ មានសុវត្ថិភាព ដល់វៀតណាម និងអនុញ្ញាត ឲ្យវៀតណាមទិញស្បៀង និងដឹកជញ្ជូនស្បៀង។

–. វៀតណាម មានភារកិច្ច ជួយហ្វឹកហាត់ បច្ចេកទេសកាំភ្លើងធំ ស៊ើបការណ៍ និងវាយពិសេស ដល់អង្គភាពដំបូងៗរបស់ខ្មែរ និងមានភារកិច្ច ដឹកជញ្ជូនអាវុធយុទ្ធភ័ណ្ឌ ដែលជាជំនួយចិនចំពោះកម្ពុជា មកផ្តល់ឲ្យកម្ពុជា។

–. វៀតណាម គ្មានសិទ្ធិវាយហ៊ុង នៅលើទឹកដីកម្ពុជាទេ។

## គ.– ចរចា និងមិនចរចា ជាមួយអាមេរិក

ឆ្នាំ1973 ឡៀយន៍ចរចា ប៉ុលពតមិនចរចា។

ពេលដំបូង លេខាបក្សទាំងពីរនេះ ប៉ះទង្គិចគ្នា៖

• វគ្គសិក្សា ឆ្នាំ1973 ឡេទុកថូថា វៀតណាមជាប់សន្យា ជាមួយអាមេរិក មកកៀបកម្ពុជា ឲ្យចរចា ជាថ្នូរ និងប្រាក់ 200លានដុល្លារ – អាវុធសឹកវាយផ្តាច់ព្រ័ត្រ ត្រូវបានពន្យា ក៏ព្រោះតែឧបាយកលកៀបនេះឯង។

• កងទ័ពវៀតណាមមួយកង ចូលទៅវាយពោធិ៍ចិនតុង ដោយបន្សល់ទុក សពយុទ្ធជន នៅលើទីលានប្រយុទ្ធ ក៏ព្រោះតែប្រាថ្នា បំភ័ន្តភ្នែកសាកលលោក ថាសមរ–ភូមិកម្ពុជា ក៏វៀតណាមជាអ្នកប្រយុទ្ធ។

ពេលបន្ទាប់មក ឡៀយន៍ ស្នើ ប៉ុលពត សុំឲ្យអាណាកងវៀតណាម វិលត្រឡប់ទៅស្រុក ទៅចូលរួមបោះឆ្នោត។ ប៉ុល ពត ព្រមបន្ថែម ឲ្យចេញ ឲ្យអស់ឆាប់។

ចាប់តាំងតែពីពេលនោះមក សែងគេអពីព្រោះអាសន្នវៀតណាម នៅលើទឹក

កាំង ហ្គេកអ៊ាវ

00787954

ដីកម្ពុជា ទៀតហើយ។

ចុងបញ្ចប់ ថ្នាក់ដឹកនាំបក្សទាំងពីររូប គឺប៉ុលពត និងឡេឌួន ប្រើវិធីបញ្ចប់សង្គ្រាមឲ្យបានឆាប់ ដើម្បីយកប្រៀបគ្នាទៅវិញទៅមក។ កម្ពុជា វៀតណាម ឡាវ ត្រូវបានរំដោះក្នុងខែមេសា1975 ទាំងអស់គ្នា គ្រាន់តែកម្ពុជារំដោះបានមុន វៀតណាម និងឡាវ 13ថ្ងៃ។

មហាជ័យជំនះខែមេសាឆ្នាំ1975 ពិតជាមានអត្ថន័យមួយធ្ងន់ណាស់ គឺធ្វើឲ្យយុទ្ធសាស្ត្រនយោបាយ អាស៊ីអាគ្នេយ៍របស់អាមេរិកប្រែប្រួល។ SEATO ដែលបង្កើតឡើងនៅឆ្នាំ1954 ដោយEISENHOWER ត្រូវបាន CARTER រំលាយនៅឆ្នាំ1977។

នេះជាយុទ្ធវិធីមួយដំហានថយក្រោយ ពីដំហានទៅមុខរបស់ CARTER។

ឃ.– អំពីខ្មែរ ដែលទៅរៀននៅវៀតណាម

មិត្តអស់នេះ ទៅដល់ស្រុកគេភ្លាម ត្រូវលាលែងសញ្ជាតិខ្មែរ យកសញ្ជាតិវៀត រស់នៅក្នុងកងទ័ពវៀតណាម រៀនមុខវិជ្ជាសព្វសារពើ ក្នុងឋានៈជាកងទ័ពវៀតណាម។ លុះដល់ឆ្នាំ1971 ពេលចូលមកដល់ស្រុកខ្មែរវិញ ត្រូវលាសញ្ជាតិវៀត យកសញ្ជាតិខ្មែរវិញ លាបក្សពលករវៀតណាម ចូលបក្សកុម្មុយនីស្តកម្ពុជា។

សម្គាល់៖ ចូលបក្សកុម្មុយនីស្តកម្ពុជា គឺត្រូវគោរពលក្ខន្តិកៈបក្ស និងរចនាសម្ព័ន្ធចាត់តាំងរបស់បក្ស។

កម្មាភិបាលខ្មែរ ដែលមកពីវៀតណាម ប្រហៅថា "ពួកហាណូយ" បានបែកចេញពីស្រុកទេស 17ឆ្នាំហើយ ម្ល៉េះហើយ លោកទស្សនៈ ជីវទស្សនៈ ប្លែកស្ទើរៈពីអ្នកនៅក្នុងស្រុក។ កម្មាភិបាលក្នុងស្រុក មានប្រៀបជាង ពីព្រោះបក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកគេជាកម្មសិទ្ធ។

ពួកមកពីក្រៅ មានសមត្ថភាពនយោបាយទាប និងអត្តនោម័តិជង ក៏ត្រូវជាបន្តបន្ទាប់។ គឺតមកត្រឹមឆ្នាំ1974 ដែលជាឆ្នាំរៀបចំការវាយសំរុកផ្តាច់ព្រ័ត្រ គ្មានពួកហាណូយជាប់ចលនាយោធាទេ។ ក្រោយ17មេសា1975 មានតែមួយចំនួនតិច ដែលនៅរស់ និងនៅជាប់ចលនា ហង់ប៊ុញ៉ា ឌុត្ត និងពាយព័ញ្ញ។ ក្រោយ6មករា1979 មានតែម្នាក់គត់ ដែលនៅជាប់ចលនា។

ពួកមិត្តអស់នេះ ជាកម្លាំងនយោបាយរបស់សហភាពសូវៀតណាចិន ហុងគ្រី មហោ-គមវិជ្ជា តែគ្មានខ្សែចាត់តាំងសម្ងាត់របស់បក្សពលករវៀតណាមទេ។

ង.– ទំនាស់បក្សទាំងពីរ សម័យឡេឌួន ប៉ុលពត

- ទិដ្ឋភាពរួម

ទំនាស់រវាងបក្សពលករវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជា ជាទំនាស់

ក់ប ហ្វេកអ៊ិន

ក្នុងពេលជាកុម្មុយនីស្តអន្តរជាតិ គឺទំនាស់រវាងប្រមូលផ្តុំ ៥បក្ស។
សហព័ន្ធឥណ្ឌូចិន ដែលវៀតណាមលើកមក មិនចាំបាច់ទេ។ ឯកភាពដ្ឋ
ម្ចាស់ការរបស់ប៉ុលពត ដោយឈរលើផ្លូវការបដិវត្ត ដើម្បីដោះស្រាយទំនាស់ក្នុងប្រជា-
ជន តែងលើសត្រូវ ដើម្បីដោះស្រាយទំនាស់ ជាមួយវៀតណាម ជាអន្តរាយដល់ជាតិ
ប្រជាជន។ មហាជាតិ ទៅហើយ ប៉ុលពត នួនជា អៀងសារី នាំគ្នាយក ក្បែរ
តែកាត់។

• ទំនាស់ពិតប្រាកដ

3 នៅចន្លោះឆ្នាំ1970 ដល់ឆ្នាំ1975 ប៉ុលពតពន្យល់ផ្ទៃក្នុងបក្សថា ខ្មែរយើងតាំងខ្លួន
ជាម្ចាស់ឥណ្ឌូចិន តាមទ្រឹស្តី "បក្សតែមួយ កងទ័ពតែមួយ......"។
ប៉ុន្តែ នៅថ្ងៃ14ឧសភា1976 ប៉ុលពតពន្យល់ថា វៀតណាមអប់រំគំនិតឥណ្ឌូចិន
ជាប់ហូត (700 ERN 00000822) ដើម្បីលេបកម្ពុជា (ERN 00000823) យកទៅប្រើ
ក្នុងការ ចរចា ព្រំដែនទឹក។
ដូច្នេះ ទំនាស់ពិតប្រាកដ គឺទំនាស់ព្រំដែនទឹក។ ទំនាស់នេះ វាមានតាំងតែពី
សម័យ ដើម ឪពុកយើងមកម្លេះ។

• គ្រោះអាសន្នសហព័ន្ធឥណ្ឌូចិន

គឺជា គ្រោះអាសន្នឧបកល្ប ដែលប៉ុលពតប្រឌិតឡើង ដើម្បីលើកអត្តភាពបក្ស
កុម្មុយនិស្តកម្ពុជា។ បក្ខជនសាមញ្ញវិលក្បាល ដោយសារតែឈ្មោះ ថ្ងៃខែឆ្នាំកំណើតបក្ស។
ថ្ងៃខែឆ្នាំកំណើត កើតពីថ្ងៃ23មិថុនា1951 មក10តុលា1951 មក30កញ្ញា1951
មក 30កញ្ញា1960។ ឈ្មោះប្រែពី បក្សប្រជាជនបដិវត្តកម្ពុជា មកជាបក្សពលករខ្មែរ
មកជាបក្សពលករកម្ពុជា មកជាបក្សកុម្មុយនិស្តកម្ពុជា។
មហាសន្និបាត តំណាងទូទាំងប្រទេស 20នាក់ នៅស្ថានីយរថភ្លើងភ្នំពេញ ជា
ការបកស្រាយបំភ័ន្ត។ ការពិត គឺមានសន្និបាតមួយតូច នៅខ្ទមស្វាយព្រៃ ថ្ងៃ10តុលា1960
ដែលធ្វើឲ្យ ស៊ីវហេង ដើរចេញពីបក្ស។
ឆ្នាំ1953 ប៉ុលពតចូលមកនៅក្នុងបក្សប្រជាជនបដិវត្តកម្ពុជា បៀបជាដៃ
មួយគ្រាប់ ចុះទៅចាប់បួសលើមែកឈើ។

• អាកប្បកិរិយានយោបាយរបស់ ប៉ុលពត ចំពោះ ខ្មែរយើង

សភាពការណ៍ រវាងវៀតណាម កម្ពុជា ធ្លាប់ចប់សព្វគ្រប់មួយពេល
ហើយ។ លក្ខណសម្បត្តិនយោបាយ ដែលវិវត្ត មកត្រឹមឆ្នាំ1973 អនុគ្រោះដល់ការ
កាត់ចង ស្មើភាព រវាងបក្ស ទាំងពីរ។
ប៉ុន្តែ នៅថ្ងៃ30មីនា1976 ប៉ុលពត បែរជាសំរេចចិត្តតែង មិនចេញទៅ
ទស្សនកិច្ច វៀតណាម ដោយយកលេសការពារសុវត្ថិភាពផ្ទាល់ (693 ERN

កាំង ហ្គេកអ៊ាវ

00 003 142) នោះបើជា កាលពីថ្ងៃ 14 ឧសភា 1976 នួន ជា បានរៀបថា "ឡេឌួន សរសេរ ឧបាយ ជាចង់រួបរួម ចង់ទៅគាំទ្រ" (700 ERN 00 000 826) ក៏ដោយ។

• សំដៅសំរាប់ ជាវិធានការគំនិតរបស់ប៉ុល ពត

ក្នុងខែមេសា ឆ្នាំ 1976 មានព្រឹត្តិការណ៍ពីរ៖

មួយ. - ថ្ងៃ 2.4.76 ផ្ទុះសង្គ្រាម - កងពល 170 - មានគ្រាប់បែកក្រោយវាំង។

ពីរ. - ថ្ងៃ 8.4.76 កុយធួន ចែលរួច ស៊ីលឈឺ ជាមួយនាក់ ហើយធ្វើឃាត ប៉ុលពត ត្រូវបានប៉ុល ពត ចាប់ដាក់ឃុំក្នុងផ្ទះ។

ថ្ងៃ 14 ឧសភា 1976 នៃក្រោយព្រឹត្តិការណ៍ពីរនេះ រយៈមួយខែ ប៉ុលពត បានដឹកនាំប្រជុំវិភាគទំនាស់ព្រំដែនកម្ពុជា វៀតណាម។ នៅពេលនោះ ប៉ុលពតលើកឧទាហរណ៍ ស្ថានភាពការណ៍ថា ទំនាស់ព្រំដែន មានលក្ខណៈជាសាកល - ប្រទេសសង្គមនិយមទំនាស់ មិនសង្គមនិយមទំនាស់។ ប្រទេសមួយ លើកកម្លាំង ទៅឈ្លានពានប្រទេសមួយទៀតបាន លុះត្រាតែ ខាងក្នុង មានកម្លាំងគ្រប់គ្រាន់ ឬមានខ្សែក្រោមក្រោយ ទើបមកបាន (700 ERN 00 000 820)។

ក្រោយអង្គប្រជុំនេះ ក៏សេចក្តីចេញពាក្យស្លោក "ចង់ឈ្នះយួន ត្រូវឲ្យបក្សស្អាត កងទ័ពស្អាត ប្រជាជនស្អាត"។ គាត់សំដៅសំរាប់បក្ស ហេតុចង់សហជីពមជ្ឈិមទៅសល់តែ 13 នាក់។ កងទ័ព - ជាពិសេសកងទ័ពមជ្ឈិម - សម្លាប់ស្ទើរតែទាំងអស់។

ចង់ឈ្នះយួនត្រូវកាប់សម្លាប់ក្នុងនៅខ្លួនឯង។ គំនិតនេះមិនប្រក្រតីសោះ។

• ដំណើរវិវត្តនៃសង្គ្រាមប៉ុលពត ឡេឌួន

សង្គ្រាម ប៉ុលពត ឡេឌួន កើតមកពីការប៉ះទង្គិចគ្នាតាមព្រំដែន (700 ERN 00 000 810)។

ថ្ងៃ 15 សីហា 1977 ប៉ុលពត ឲ្យលុកលុយ គោលដៅទាំងនៅមុខសៀង។

ថ្ងៃ 31 ធ្នូ 1977 ប៉ុលពត ប្រកាសសង្គ្រាម ជាមួយ ឡេឌួន។

ថ្ងៃ 6 មករា 1978 ប៉ុលពត ធ្វើមិទ្ទិញ ប្រកាសជ័យជំនះ លើកងទ័ពវៀតណាម។ នៅពេលនោះ ប៉ុលពត ឧទ្ទេសនាមថា "កសិករក្រ ឋានកណ្តាលថ្នាក់ក្រោម ជាវណ្ណៈដឹកនាំ"។

សម្គាល់៖ នេះជាដំបានថ្មីមួយទៀត នៃលទ្ធិម៉ាក្ស ឡេនីន។

ថ្ងៃ 8 មករា 1978 នួន ជា បញ្ជាឲ្យស.21 ចាត់ចម្លើយឈ្លើយសឹកវៀតណាម មួយអាទិត្យពីរនាក់។ គាត់យកទៅផ្សាយវិទ្យុ។

បញ្ជាក់៖ ឈ្លើយសឹក ចំនួនដែលស៊ីវិលវៀតណាមមួយចំនួន ចាប់យកមកពីទឹកដីវៀតណាម។

ខែ សីហា 1978 ប៉ុលពតបើកវគ្គនយោបាយប្រចាំឆ្នាំ។ ប៉ុលពតឧទ្ទេសនាមជា ពេជ្រថា៖

• ឆ្នាំ 1979 យើងភៀសខ្លួនចេញទាំង នៅភ្នំឡុក ដងឡុកចន្ទា ខេត្តតាយចន្ទា។

កាំង ហ្គេកអ៊ាវ

• លក្ខណៈវិបត្តិ មតិត្រឹមត្រូវគឺជ័យជម្នះ – "មតិត្រូវឈ្នះ"

• យើងរៀន "សីលធម៌បដិវត្តន៍" ទាំងអស់គ្នាឡើងវិញ។

សម្គាល់៖ ក្រោយកំណើតមិនមែនសីលធម៌បដិវត្តន៍។ ក្រោយកំណើតលោកមកសីលធម៌បដិវត្តន៍។ សីលធម៌បដិវត្តន៍ គឺ "បំរើប្រជាជនកម្មករកសិករឲ្យអស់ពីចិត្តពីថ្លើម ដោយមិនគិតពីផលប្រយោជន៍ ឆាប់នេះជាខ្លួនចំពោះមុខ"។

ថ្ងៃ 30 កញ្ញា 1978 ប៉ុល ពត នួន ជា អៀង សារី ប្រារព្ធបុណ្យកំណើតបក្ស ខួបទី18។ នេះជាលើកទីមួយ ហើយក៏ជាលើកចុងក្រោយបំផុតផងដែរ ដែលកំពូលដឹកនាំបក្ស ទាំងបួននេះ អង្គុយជុំគ្នា លើវេទិកាអធិបតី (E3/6 ERN 00294001)។

២ ថ្ងៃ 7 មករា 1979 វេលាម៉ោង 11 ថ្ងៃត្រង់ ទ័ពរំដោះវៀតណាម ចូលតាមមហាវិថីមុន្នីវង្ស មកដល់មុខផ្ទះខ្ញុំ។

• ស្វែងយល់លោកទស្សនៈមួយចំនួន ទាក់ទងនឹងសង្គ្រាម

ប៉ុល ពត នួន ជា អៀង សារី យកសង្គ្រាមជាគ្រឿងមុខ ក្នុងការដោះស្រាយទំនាស់។

ផ្ទុយពីពួកនេះ គឺ ស្ដេចតែង អនុវត្ត ព្រះបន្ទូលរបស់ព្រះគ្រីស្ទជាម្ចាស់ ដែលថ្លែងថា៖ "ត្រូវស្រឡាញ់ ខ្មាំងសត្រូវរបស់អ្នក" (ម៉ាថាយ ជំពូក 5 ខ 44)។ បើមិនបាន ពុទ្ធោ អនុវត្តព្រះបន្ទូលនេះ យ៉ាងស៊ីតស្លាប់ទេ ម៉េះលិម ឈាមចិន ឈាមវៀតណាម ឈាមខ្មែរ ហូរមិនដឹងជាអស់ប៉ុន្មានម៉ឺន ហើយតាំងពីជាតិ ទៅជាតិបន្ត។

ស្នេហាជាតិ មិនប្រើសង្គ្រាម ដោះស្រាយទំនាស់ទេ។

ចាស់ៗជំនាន់មុន ធ្វើឲ្យកម្ពុជា និងវៀតណាម ផ្ទុះសង្គ្រាម។ យើងជំនាន់នេះ និងជំនាន់តទៅ ជាអ្នកដោះស្រាយ។ ទាល់តែយើងដោះស្រាយ ទើបដោះស្រាយបាន។ គ្មាននរណា ដោះស្រាយបានល្អ ជាងយើងទេ។

ម្យ៉ាងទៀត ចំពោះមុខនេះ យើងទាំងអស់គ្នាមានកាតព្វកិច្ចមួយ គឺរួមចំណែក សំរេចផ្សះផ្សាជាតិ តាមគោលគំនិតច្បាប់ នៃការបង្កើត អ.វ.ត.ក ចុះថ្ងៃ 27 តុលា 2004 ឲ្យបានត្រឹមត្រូវ ដោយរួមទាំងភារកិច្ចពីរ៖

មួយ.- បង្ហាញ ការពិត ជូនប្រជាជនកម្ពុជា។

ពីរ.- ទម្លាក់ការទទួលខុសត្រូវ ទៅលើវៀតណាម និងកម្ពុជាក្រោម។

ធ្វើបែបនេះ ប្រៀបបានដូចយកស្លឹកអំពិល តែពីរក្នុងសន្លឹក យកទៅបិទបាំង ភ្លូង អកសាច នៃរាងកាយ។



តាំង ហ៊េកអ៊ាវ

00787958

ជំពូកទី 2

# ស្វែងយល់មាគ៌ាសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា

ក្រោយ17មេសា សង្គមកម្ពុជាមានលក្ខណៈដូចតទៅ៖

-. មធ្យោបាយផលិតកម្ម ទាំងអស់ ស្ថិតនៅក្នុងកណ្ដាប់ដៃរបស់បក្ស

-. ជំរាប់នោះ "ម្នាក់ៗ ធ្វើការតាមសមត្ថភាព ទទួលផលតាមការចាំបាច់"

-. ទាំងអស់គ្នា វាយសំរុក តាំងពោះត្រែហែត

## I.- ជំលៀស និងសំអាតសំរាំងប្រជាជន

ជំលៀសប្រជាជន ជាផែនការត្រៀមឈ្នះ។

ប្រជាជនកម្ពុជាទាំងអស់ ដែលរស់នៅក្នុងភ្នំពេញ និងតាមទីប្រជុំខេត្ត ត្រូវបានបញ្ចេញចេញពីផ្ទះ ឲ្យទៅនៅជនបទ។ ក្នុងពេលជំលៀសនេះ មានពលជាតិទេ។

ប្រជាជន ដែលនៅរស់ពីតំរេច ត្រូវបានចាត់តាំងឲ្យទៅរស់នៅ នៅក្នុងសហករណ៍។ សហករណ៍កំរិតខ្ពស់ត្រូវបានបង្កើត ឲ្យមានវិសាលភាព ទូទាំងប្រទេស ដោយសេចក្ដីសំរេចចិត្ត ថ្ងៃ 20 ឧសភា 1975។

នៅក្នុងសហករណ៍ ប្រជាជនចាស់គ្រប់គ្រងប្រជាជនថ្មី (កថាខណ្ឌ 166 ERN 00 078 022) ទាំងអស់គ្នា ស្ថិត នៅក្រោម ការចាត់ចែង គ្រប់គ្រងរបស់សាខាបក្សសហករណ៍។ មនុស្សចំនួន 85% នៃប្រជាជនកម្ពុជា ស្ថិតនៅក្នុងសហករណ៍។

កម្មករ ត្រូវបានដកជញ្ជូន ត្រឡប់មករោងចក្រវិញ អស់មុនថ្ងៃ 31 ឧសភា 1975 មករស់នៅប្រមូលផ្តុំ និងធ្វើសកម្មភាព បង្កបង្កើនផល តាមរោងចក្ររៀងខ្លួន ក្រោមការគ្រប់គ្រងចាត់ចែង របស់សាខាបក្សសហជីព។

គ្មានប្រជាជនណាម្នាក់ រស់នៅសេរីអត់អង្គភាពទេ។

ស្រុកកម្ពុជា ជាផ្ទះរបស់ប្រជាជនកម្មករ កសិករ និងពលករផ្សេងទៀតទាំង

កាំង ហ្គេកអ៊ាវ

អស់ (D2/447 TSL ERN 00 089 845 មាត្រា 1 នៃរដ្ឋធម្មនុញ្ញ)។

II.– កិច្ចដំណើរការ ពង្រឹងរដ្ឋកម្ពុជាប្រជាធិបតេយ្យ

ដើម្បីសំរេច គោលដៅយុទ្ធសាស្ត្រថ្មីបច្ចុប្បន្ន (លក្ខន្តិកៈបក្ស ERN 00 053 010 កថាខណ្ឌទី3) បក្សបានប្រើវិធានការពីរ ៖

មួយ.– ជំលៀស

- ឆ្នាំ 1974 ជំលៀសប្រជាជនឧដុង្គ យកទៅទុកបំពោធិ៍សាត់។
- ថ្ងៃ 17 មេសា 1975 ជំលៀសទូទៅ។
- ថ្ងៃ 30 វិច្ឆិកា 1975 ជំលៀសពីបូព៌ា យកទៅឧត្តរ និងពាយព្យ។

21 ពីរ.– កំទេច

កំទេច គឺជាការអនុវត្ត ផ្តាច់ការបដិវត្ត តាមគោលការណ៍ប្រជាធិបតេយ្យសង្គមនិយម (693 ERN 00 003 136 កថាខណ្ឌទី1)។

អ្នកដែលមានសិទ្ធិ សំរេចកំទេច គឺ អចិន្ត្រៃយ៍បក្ស អចិន្ត្រៃយ៍ភាគ គណៈមន្ទីរ មជ្ឈិម និងលេខាធិការ។

ក្រោយថ្ងៃ 30 មិនា 1976 មានលេខាភាគពីរនាក់ ត្រូវបានចាប់ខ្លួន មកពីអត្តនោមតិ សំរេចកំទេច តាមបុគ្គលនិយម។

ឯកសារ D93/III E3/86 និង E52/4.62 បញ្ជាក់ថា មានតែ ប៉ុល ពត នួន ជា ហ៊ុង ដៀន ទេ ទើបមានសិទ្ធិពិតប្រាកដ ក្នុងការសំរេចកំទេច។

III.– កសាងកសិកម្ម ជីវាន់កម្ពុជាប្រជាធិបតេយ្យ

ផ្នែកកសិកម្ម បក្សកុម្មុយនីស្តកម្ពុជា ពឹងលើស្រូវជាធំ។ ក្រៅពីស្រូវ មានផលិតកម្មខ្លះ ដូចជាសូត្រ ជាដើម បក្សបំភ្លេចចោល។

ផ្នែកស្រូវ ផែនការ ដែលផ្សព្វផ្សាយ គឺបីតោនមួយហិកតា។ ដើម្បីសំរេចបីតោន ពន្លឺះ គឺត្រូវដោះស្រាយ ទឹក ដី និងពូជ ។ តែក្នុងការអនុវត្ត បក្សបែរជាវាយសំរុកប្រព័ន្ធភ្លឺ ដែលគមការកម្លាំងដ៏ធំនិងស្រួច ធ្វើឲ្យខ្វះកម្លាំងផ្នែកទឹក និងផ្នែកដី ប៉ះពាល់ដល់3តោន ម៉្លោះហើយ មជ្ឈិម ត្រូវតែអន្តរាគមន៍ ប្រចាំសប្តាហ៍ (693 ERN 00 003 136 កថាខណ្ឌទី2)។

អាទិភាពកសិកម្ម ត្រូវឈរលើសមូហភាពូបនីយកម្ម និងយន្តកម្ម គឺស្រែត្រូវតែធំ ដើម្បីឲ្យម៉ាស៊ីនកសិកម្ម វាធ្វើការបានពេញកម្លាំង បង្កើនទិន្នផលឲ្យបានខ្ពស់ ចំណាយទុនដើមតិច តាមគោលការណ៍ធនលាភីយភាព។ ប៉ុន្តែ នៅទសវត្សឆ្នាំ ៧០ ស្រែមួយៗ មានទំហំលើសពី 400 ហិកតា។ ស្រូវ 8 តោន មួយហិកតា មួយរដូវ។



កាំង ហ្គេកអ៊ាវ

សង្កេតៈ ក្នុងការជ្រើសរើស កសាងប្រព័ន្ធភ្លឺ ទំនប់ប្រឡាយ ស្រោចស្រព គេតាមបច្ចេកវិទ្យា គេប្រើមូលធន កម្លាំងម៉ាស៊ីន និងពេលវេលាមួយសមស្រប។

បក្សកុម្មុយនីស្តកម្ពុជា យកគំរូតាម "កងផលិតផលិតាចាយ" បានកេណ្ឌកម្លាំងជាតិទាំងមូល មកសាងប្រព័ន្ធភ្លឺទំនប់ដាក់ដៃ បានតែមួយឆ្នាំ គឺនៅថ្ងៃ 21 មេសា 1976 ប៉ុល ពត បានសំរេចឲ្យនាំភ្ញៀវបរទេស មកទស្សនកិច្ចមួយនៅ ដំរីកា បឹងទន្លេសាប (D00 694 ERN 00 019 143-144) ដើម្បីបង្ហាញ អំពីការកសាងសង្គមនិយម ដោយល្បឿនមហាលោតផ្លោះ។

សង្កេតៈ បីតោន មួយហិកតា អត់តម្លាភាពទេ។ 2

## IV.- ប្រៀបធៀបការកសាងសេដ្ឋកិច្ច ក្រោមរបបនយោបាយពីរ

មួយ.- ក្រោមរបបប្រជាធិបតេយ្យថ្មីរបស់ ម៉ៅ ជីតុង

ឯការ "ប្រជាធិបតេយ្យថ្មី" កំណត់ នៅឆ្នាំ 1940។ ម៉ៅ ជីតុង ឲ្យតម្លៃ ទៅលើវណ្ណៈទាំងបួន គឺ កម្មករ កសិករ អនុធន និង ពាណិជ្ជករជាតិ។ ឧត្តមគតិនេះ ត្រូវបានចារឹកទុក នៅលើ ទង់ក្រហមផ្កាយប្រាំ ដែលជាទង់ជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន។ ផ្កាយធំ តំណាងបក្សកុម្មុយនីស្តចិន ផ្កាយតូចទាំងបួន តំណាងវណ្ណៈទាំងបួន។

ពីឆ្នាំ 1966 ដល់ឆ្នាំ 1976 ប្រជាធិបតេយ្យថ្មី ត្រូវបាន បដិវត្តន៍វប្បធម៌បំផ្លាញ នាំឲ្យ សេដ្ឋកិច្ចជាតិធ្លាក់ចុះ ជីវភាពប្រជាជនទុនទាប។

ឆ្នាំ 1977 ក្រោយពីឃាត់ខ្លួនក្រុមបួននាក់ តឹង សៀវភីង បានរៀបចំមាគ៌ាបក្សឡើងវិញ។

ឆ្នាំ 2010 ចិនបានឡើងជាមហាអំណាចសេដ្ឋកិច្ចលំដាប់លេខពីរ។ តម្លៃជីវភាព ប្រជាជនចិន គិតជាមធ្យម 3ពាន់ដុល្លារ។

សង្កេតៈ កាលពីឆ្នាំ 1997 Gary TIFFIN ព្រឹទ្ធបុរស នៃមហាវិទ្យាល័យព្រះគម្ពីរនៃ មហាសាគរប៉ាស៊ីហ្វិក បាននិយាយថា ជាងកាយជាក និងក្រុមគ្រួសារ ជាគ្រីស្ទាន តែគាត់ មើលឃើញ តែគ្រីស្ទាន មើលមិនឃើញកសិករ។ ទើបព្រះអម្ចាស់ លោកប្រគល់កសិករចិន ទៅឲ្យ ម៉ៅ ជីតុង។ TIFFIN បានពន្យល់តទៅទៀតថា តឹង សៀវភីង គឺជាគ្រីស្ទានបង្កប់ តែគាត់ ស្ងៀម ទៅជាសម្ងាត់។

ពីរ.- ក្រោមរបបប្រជាធិបតេយ្យសង្គមនិយមរបស់ប៉ុល ពត

របបប្រជាធិបតេយ្យសង្គមនិយមរបស់ប៉ុលពត មានលក្ខណៈដូចតទៅ÷

- ទទួលស្គាល់តែវណ្ណៈកម្មករ និងកសិករ (លក្ខន្តិកៈបក្ស ជំពូក ទំព័រ 2 បន្ទាត់ទី4 និងទី5 D00 674 ERN 00 053 010)។
- សេដ្ឋកិច្ច គឺជាថ្នាលបណ្ដុះបណ្ដាលកម្មករ កសិករ ឲ្យប្រកាន់ តួនាទីដឹកនាំ តាមរយៈ ជ្រើសរើសស្រុកគំរូ (693 ERN 00 003 136 កថាខណ្ឌទី3) ទស្សនកិច្ចសិក្សា (693 ERN



តាំង ហេកមិរ

00 003 137 កថាខណ្ឌទី4) ចំនួនលក្ខណសម្បត្តិ 10 យ៉ាង (D00 674 ERN 00053 020-023)។

•គេមិនប្រើរបបធ្វើ បែងចែកផល តាមគោលការណ៍នៃរបបសង្គមនិយមទេ ពីព្រោះបែងចែកផលតាមសមត្ថភាព ត្រូវការប្រើលុយ និងជួសកម្មសិទ្ធិឯកជន។ គេអនុវត្តរបបនៃរបបកុម្មុយនិស្ត គឺ "ផ្តល់គេម្នាក់ៗ តាមការចាំបាច់"។ ការចាំបាច់គឺអង្ករហូប គ្មានសេវាកម្មសុខាភិបាល គ្មានសិក្សាធិការ។

របបអង្ករ ដំណាក់ដំបូង មានពីរប្រភេទ៖

-.ក្នុងប្រជាជន៖ កម្លាំងស្រួច កំពុងសាំក្រការងារ 2 កំប៉ុង កម្លាំងលេខមួយ 1 កំប៉ុងកន្លះ។

4 -.ក្នុងកងទ័ព៖ កម្លាំងស្រួចកំពុងសាំក្រការងារ 2 កំប៉ុងកន្លះ កម្លាំងលេខមួយ 2 កំប៉ុង (D00 677 ERN 00 019 126)។

ប្រៀបធៀប៖ នៅក្នុងទសវត្សឆ្នាំ60 កម្មករខ្សត់វេសាខម្នាក់ ហូបបាយក្រុមហ៊ុន បានម្នាក់ៗ 1ថ្ងៃ 10៛ ដែលអាចទិញអង្ករបាន 3 ទៅ 4 គីឡូ គឺ 10 កំប៉ុងទៅ 13 កំប៉ុងកន្លះ។

## V.- ស្វែងយល់ អំពីខុនសំរាប់កសាងប្រទេស

ខុន សំរាប់កសាងប្រទេស មានបួន គឺមធ្យោបាយផលិតកម្ម កម្លាំងពលកម្ម តំរិះ-ប្រាជ្ញា និងមូលធន។

### ក.- មធ្យោបាយផលិតកម្ម

មធ្យោបាយផលិតកម្ម គឺមធ្យោបាយសំរាប់បង្កបង្កើតផល ទាំងអស់ គឺដីស្រែ ដីចំការ រោងចក្រតូចធំ រោងកម្មន្តសាល មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សម្បត្តិធម្មជាតិ លើដី ក្រោមដី ក្នុងទឹក គឺទាំងអស់។

• មុន 17 មេសា 1975

រោងចក្រខ្លះ ដូចជារោងចក្រតម្បាញកំពង់ចាម ជាដើម ជារបស់រដ្ឋ អគ្គិសនីកម្ពុជា ជារបស់ក្រុមហ៊ុនចំរុះ-រដ្ឋឯកជន រោងចក្រតម្បាញដីបតុង ជារបស់ឯកជន។ ដីស្រែ ដីចំការ ជារបស់ឯកជន- ឯកជនជាក្រុមហ៊ុន ឯកជនជាបុគ្គល។ ដីទំនេរខ្លះ ជារបស់រដ្ឋ ដែលអោយឯកជន ធ្វើអាជីវកម្ម។

• ក្រោយ 17 មេសា 1975

មធ្យោបាយផលិតកម្ម ទាំងអស់ បានក្លាយមកជារបស់បក្ស (ខ្សែធម្មនុញ្ញ មាត្រា 2 ERN 00 089 845)។ ចប កាំបិត ប៉ូវថៅ ដោយម្ចាស់វា ជាកម្មសិទ្ធិរបស់បក្ស វាក៏ជាកម្មសិទ្ធិប្រយោលរបស់បក្ស។

នៅលើសាកលលោកនេះ គ្មានបក្សណាមួយ ឡើងកាន់អំណាចធ្វើបានដូច្នេះទេ។ សមិទ្ធិនេះ មានអានុភាពដាច់ខាត និងទាំងស្រុង នៅលើអត្តភាពរបស់ប៉ុលពត ដូចជា ម៉ុងហ្វឿន

កាំង ហ្គេកអ៊ាវ

00787962

ធ្វើឱ្យពួកនេះ លង់លក់ក្នុងសុបិន សន្តិសុខម្ចាស់ការ ។

3.- កម្លាំងពលកម្ម

គោលនយោបាយកម្លាំងពលកម្ម ដ៏ចាស់នោះ មានចំនួនភាគតិច ដែលផុយពីក្នុងទីក្រុង គឺប្រមូល និងសំពិតសំពាំង ដែលធ្វើតាមគំនិតរបស់ "បដិវត្តន៍វប្បធម៌" ។

• ប្រមូល

គឺប្រមូលកម្លាំងជាតិកំលាំង ដោយជំលៀសប្រជាជន ផ្សឹកលោកសង្ឃ បិទសាលារៀន បិទពេទ្យ បិទមុខរបរទាំងអស់ ដែលមិនផលិតស្រូវ មិនផលិតគ្រឿង និងមិនផលិតកសិកម្ម គឺប្រមូលទាំងអស់ ឱ្យចុះទៅជាប់ស្រែ ទៅលត់ដំខ្លួន ។ 2

• សំពិតសំពាំង

គឺសំពិតសំពាំងមនុស្ស ដោយបុព្វហេតុដ៏ល្អ: ការពារលទ្ធផលបដិវត្ត បង្ការបដិវត្តន៍អនុផល ជាយខុន (លក្ខន្តិក:បក្ស ERN 00 053 010) កុំឱ្យជំលៀបួជ ។

មនុស្សតែង 1លាន 7សែននាក់ ដែលកំណត់ទៅនេះ ពិតជាស្រឡាញ់ សន្តិភាព ត្រូវការយុត្តិធម៌ ចង់កសាងជីវភាព ឱ្យសម្បូរថ្កើងឡើង ។ ប៉ុន្តែពួក ខួនជា ម៉ុងឡើន ក៏សាងតែបង្ខំ កម្លាំងនេះ ពិតជាប្រយោជន៍ បំពេញការកិច្ច អ្វីក៏បាន ។ បើទៅលើក ដីទំនប់ ក្នុងមួយថ្ងៃ លើកបាន 1ហ៊ឺន 7សែន ម៉ែត្រគូប ដែលអាចពង្រីក ជីកដី 1ម៉ែត្រ នៅលើថ្ងៃ 1លាន 7សែន ម៉ែត្រការ៉េ គឺធំជាងផ្ទៃដី អង្គរវត្ត លើសពីមួយដងកន្លះ ។

ដីចំការ 1លាន 7សែននេះ បក្សកុម្មុយនីស្តកម្ពុជា ត្រូវតែទទួលខុសត្រូវ ។

បើនិយាយត្រឹមតែ អំពីកម្លាំងពលកម្ម ក៏ឃើញថា ប្រទេសជាតិយើង បាត់បង់ធនធានណាស់ គឺបាត់បង់ កំលាំងពលកម្ម ដែលជាកម្លាំងកាយ បាត់បង់កំលាំងពលកម្ម ខួរក្បាល ។

គ.- ភោគៈទ្រព្យមនុស្ស

ចំណោះវិជ្ជា ខួរក្បាលសាស្ត្រ ខួរបច្ចេកទេស និងជំនាញគ្រប់ប្រភេទ ដែលបានក្លាយទៅជា ភោគៈទ្រព្យរបស់មនុស្សអស់ទៅហើយ ជាប្រភព មិនចេះរីង ស្ងួត នៃពលកម្មខួរក្បាល ។

ក្រោយ 17 មេសា 1975 ជាតិយើង បាត់បង់ធនធានអស់ហើយ ។

• ជាយខុន ចំរបញ្ញាជន មួយចំនួន គេចចេញបរទេស យកភោគៈទ្រព្យរបស់ខ្លួន ទៅរួមចំណែក កសាងប្រទេសគេបំបាយ ។

• ជាយខុន បញ្ញាជន និងអនុផល ដែលនៅក្នុងប្រទេស ត្រូវបក្សកំទេច អ្នកដែលនៅរស់ មកពីគេចលាក់ ប្រែវត្តិរូប បន្លំយកសុខក្នុងសហករណ៍ ។

នេះ គឺមកពីបក្ស ប្រកាន់គោលជំហរជាច់ខាត ការពារលទ្ធផលបដិវត្ត ។

នៅក្នុងសេចក្តីថ្លែងការណ៍ ថ្ងៃ 17 មេសា 1978 នៅពហុកីឡាដ្ឋានជាតិ អ្នកឡាំពីក



តាំង ហ្វេតអាំង

បុគ្គល បានលើកឡើងថា៖ "ពោះកងណាឡើងខ្ពស់ជាង ចាយហ៊ុំ ឈ្មោះហ៊ុំ ធ្វើស្រែមាន ស្រូវហូប"។

និយាយនេះ គឺប្រកាសថា គាត់ជាកំពូលអ្នកចេះដឹង ធ្វើម៉ាក់កើត។

សង្គមកម្ពុជា ដំណាក់នោះ៖ សមដូចពាក្យចាស់លោកថា "ចាំខ្លាក់ ទមក្ដិ"។

ឃ.- ស្វែងយល់អំពីមូលធន

មូលធន គឺលុយ វត្ថុបរិយវត្ថុតម្កល់។

បក្សកុម្មុយនីស្តកម្ពុជា បដិសេធកម្មសិទ្ធិឯកជន តាមគ្រប់ប្រភេទ។ ក្រដាសប្រាក់ បោះពុម្ពហើយ ក៏មិនប្រើ។ តាមឯកសារថ្ងៃ 1ឧសភា1976 គ្រាន់តែសំរាប់បោះពុម្ព ហើយប្តូរ ជំរើស (693 ERN 00 003 140)។

គោលនយោបាយ ចាយវាយចំពោះលទ្ធិសំវៃ ច្រើនតែធ្លាក់ទៅកាន់សំរៀបណាមួយ ក្នុងចំណោម សំរៀបពីរ។

• សំរៀបទីមួយ គឺចាយធំពេក

ចាយធំពេក ដំណាក់គេច្រើន សំរាកដោះស្រាយណាស់។

សូមជូនសភាពការណ៍បច្ចុប្បន្ន ដែលយល់ដឹងជាសាកលទៅហើយ។ បំណុល របស់ក្រិក ចាត់ទុកសហគមន៍អឺរ៉ុប ឃើញថាលំបាក ផ្លូវដោះស្រាយ។ ដំបូង គឺនៅពេល ទទួល អូឡាំពិក 2004 ក្រិកចាយអស់ច្រើន។ បន្ទាប់មក ក៏អនុវត្ត គោលនយោបាយបង្កើន សមត្ថភាពទិញរបស់ពួកមន្ត្រី តាមលក្ខណៈប្រជាធិបតេយ្យ ដោយផ្តល់ប្រាក់ខែ ចំនួន14ខែ សំរាប់ រយៈពេលមួយឆ្នាំការងារ។

• សំរៀបទីពីរ គឺលទ្ធិសំវៃ ក្នុងលក្ខណៈដុតឱ្យខ្លោច

បក្សកុម្មុយនីស្តកម្ពុជា បានកៀបកៀត របបហូបចុករបស់ប្រជាជនទូទាំង ប្រទេស ដើម្បីសំវៃស្រូវអង្ករ ទុកលក់យករូបិយប័ណ្ណ។ ដើម្បីសំវៃរូបិយប័ណ្ណ ដែលគេ មានមក បក្សមិនចំណាយទិញថ្នាំពេទ្យទេ តែបែរជាបដិសេធកម្ម សុទ្ធតែពាក្យបាល ទៅវិញ។ គោលដៅ សន្សំសំវៃបែបនេះ ហៅថាដុតឱ្យខ្លោច។

ចាយវាយ បែបប្រជាធិបតេយ្យ មិនល្អមែន តែសន្សំសំវៃបែបដុតឱ្យខ្លោចគឺ ជាគ្រោះថ្នាក់ធំ។

## VI.- វិភាគវណ្ណៈក្នុងសង្គមកម្ពុជាដំណាក់ប៉ុលពត

មុន 18មីនា1970 សង្គមកម្ពុជាមានវណ្ណៈប្រាំ គឺ សក្តិភូមិ ធាយទុន អនុធន កសិករ និងកម្មករ។ ក្រោយ17មេសា1975 បក្សកុម្មុយនីស្តកម្ពុជា ទុកតែវណ្ណៈពីរ ទេ គឺកម្មករ និងកសិករ។

ដំណាក់នោះ៖ កម្មករ កសិករ យុទ្ធជន យុទ្ធនារី ទាំងអស់គ្នា បានក្លាយទៅជាទាសៈ

កាំង ហ្គេកអ៊ាវ

គ្រប់គ្នាទាំងអស់ គឺព្រោះ៖

-. នរណាក៏បាត់បង់កម្មសិទ្ធិផ្ទាល់ អស់ហើយ។

-. នរណាក៏បាត់បង់សិទ្ធិ ជាមូលដ្ឋានរបស់មនុស្សអស់ហើយ។

-. បក្សជាម្ចាស់ គ្រប់គ្រង និងចាត់ចែង លើមនុស្សទាំងអស់ តាមរយៈ បក្ខជន និង កម្មាភិបាល (លក្ខន្តិកៈបក្ស ERN 00 053 034 មាត្រា 23 ខ3)។

-. បក្សជាម្ចាស់លើអាយុជីវិតមនុស្សគ្រប់រូប ដែលបក្សអាចសំរេចកំទេច នៅពេលណាក៏បាន ដោយគ្មានជំនុំជំរះ (693 ERN 00 003 136)។

ដូរទាំងមូល ដែលឧទ្ទិសជីវិត ចូលរួមតស៊ូបដិវត្ត ដើម្បីសំរេចឧត្តមគតិ "រំដោះប្រជាជន សង្គ្រោះប្រជាជន និងបំរើប្រជាជន" តាមខ្លឹមសារ នៃចំរៀង "ឈាម ក្រហម" ក៏បានធ្លាក់ខ្លួន ទៅជាទាសៈ អស់ហើយដែរទៅ សូម្បីតែនិយាយអីក៏មិនកើត។ 12

សក្តិភូមិម្ចាស់ករៈ ដែលជាម្ចាស់លើអ្វីៗទាំងអស់ គឺសន្តតិវង្សថ្មី របស់ ប៉ុល ពត នួន ជា និង អ៊ុង ជឿន ដែលនៅពេលនោះ កំពុងតែ សហការគ្នាផង និង ដើរឱ្យបានយកល តាមផលប្រយោជន៍របស់ខ្លួន រៀងៗខ្លួន (E36-ERN 00 294 001)។



កាំង ហ្គេកអ៊ាវ

00787965

## ជំពូកបី

## អំពីសាសនា និងជំនឿគ្រប់បែបយ៉ាង

3]

បក្សកុម្មុយនីស្តកម្ពុជា លុបបំបាត់សាសនា និងជំនឿទាំងអស់ តាមវិធានការមួយច្បាស់លាស់ និងយូរអង្វែង។

### I.– កម្លាំងរស់របស់ពុទ្ធសាសនា និងទិសដោះស្រាយ

កម្លាំងរស់ របស់ពុទ្ធសាសនា គឺមានតាំងលោកសង្ឃ និងគ្រហស្ថ រួមទាំងអស់ មានលើស ពី 85% នៃប្រជាជនកម្ពុជា។

"ទង់បដិវត្ត" ឆ្នាំ 1973 ពន្យល់ថា÷

–. ចំណុចខ្សោយ របស់ពុទ្ធសាសនា ខាងកាយហិនយាន គឺលទ្ធិកម្មផល។ ជឿកម្ម ជឿផល នាំឲ្យមនុស្ស មិនហ៊ានតស៊ូ

–. តែចំណុចខ្លាំង របស់ពុទ្ធសាសនាស្រុកខ្មែរយើង ធំធេងណាស់ ពីព្រោះ: លោកសង្ឃ ជាប់និងកសិករ តាំងខាងសេដ្ឋកិច្ច តាំងខាងនយោបាយ – លោកសង្ឃជាកូនចៅកសិករ ព្រោះលោកសង្ឃ ផ្សារនិងឆ្នាំងបាយកសិករ – បើកសិករឲ្យដាច់-ដាច់ បើកសិករឲ្យរស់-រស់។

ប្រមូលកម្លាំង កសិករ គឺគន្លឹះ ជាមូលដ្ឋាន។

### II.– អំពីការងារប្រមូលកម្លាំងសង្ឃ

ប្រមូលកម្លាំងសង្ឃ គឺជាគោលនយោបាយរបស់បក្ស។



កាំង ហ្គេកអ៊ាវ

00787966

ម៉ៀន ប៉ាន់ស៊ីន ដែលនាំលទ្ធិអាក្រក់ឡេនីនចូលស្រុកខ្មែរ បង្ខំបង្កើតគណៈសង្ឃនៅក្រៅលោកសង្ឃ។ ស៊ីន ផ្ទុកម៉ឺក្តូ នឹង ខុសាមុគហារអន្ទិត។ បណ្ដាលមក ទើបថ្មីអន្តរជាតិភាពផ្លូវ-ពល ទាំងពីរនេះ ប្រមូលផ្តុំកសាងកម្លាំងបដិវត្តន៍។

ក្រោយឆ្នាំ 1956 ការប្រមូលកម្លាំងសង្ឃ ស្ថិតនៅត្រឹមតែ ជាការប្រលះយក លោកសង្ឃ ម្តងមួយអង្គ ពីរអង្គ ឲ្យមកចូលរួមធ្វើបដិវត្តន៍។

ក.– មុន 18 មិនា 1970

• នៅភ្នំពេញ មានមជ្ឈដ្ឋានកសាងកម្លាំងសង្ឃពីរកន្លែង គឺវត្តកំសាន្តសាមគ្គី ឡាអំពៅ របស់ចៅអធិការ អេង ម៉ឹក និងកុដិរបស់អ៊ុង ដឿន នៅវត្តមហាមន្ត្រី។ ២

• នៅជនបទ មានច្រើនកន្លែង ពីព្រោះនៅឆ្នាំ 1968 មានលោកសង្ឃច្រើនអង្គដែរ ដែលត្រូវ គេចាប់ផ្សឹក ដាក់គុកឃោឃៅព្រៃស។

ខ.– ពីឆ្នាំ 1970 ដល់ឆ្នាំ 1975

• នៅមូលដ្ឋានបដិវត្តន៍ លោកសង្ឃទាំងអស់សឹកទៅធ្វើបដិវត្តន៍អស់ ចាប់តាំងតែពីឆ្នាំ 1973 មក វត្តអារាមនានា ក៏ត្រូវទុកចោលទទេ អត់មនុស្សថែរក្សាការពារ ម្លោះហើយ មិនដឹងជាខូចខាតបាត់បង់ ស្ទើរទេ។

• នៅតំបន់រំដោះថ្មី ជំនួសបក្ស តែងតាំងមេគណខេត្ត តាមរយៈសន្និបាតសង្ឃ។ លោកគ្រូមេគណខេត្ត មានភារកិច្ច និមន្តតាមវត្ត គ្រប់វត្ត ចលនាលោកសង្ឃឲ្យសឹក ចូលធ្វើទ័ព។ គេយកស្លាកស្នេហាជាតិ និងទស្សនៈសភាពការណ៍ យកទៅអប់រំ។ គេយកលោកសង្ឃ ទៅចលនាលោកសង្ឃ តាមភាសិតខ្មែរ "យកមាន់ ទាក់មាន់ យកខ្លា ទាក់ខ្លា"។

គ.– ក្រោយ 17 មេសា 1975

• នៅជនបទ លោកសង្ឃទាំងអស់ ត្រូវតែសឹក។ ភិក្ខុអង្គណាមិន ទាំងត្រូវកំទេច។ ព្រះតេជគុណប្រាក់ សយ ចៅអធិការវត្តត្រែងទំពាំង ស្រុកគោកមាស ជាករណីមួយ។

• នៅភ្នំពេញ និងតាមទីរួមខេត្ត ថ្នាក់ដឹកនាំសង្ឃទាំងអស់ រាប់ចាប់តាំងតែ ពីមេគណខេត្ត ដល់សម្តេចសង្ឃ បើភៀសទៅបរទេស មិនទាន់ទេ ពិតជាត្រូវកំទេច។ កំទេចនេះ មិនមែនដោយសារចំពោះការឃោរឃៅ និងមិនមែនដោយសារបញ្ជាដឹកទេ គឺ មកពីលោកមានតួនាទី ដឹកនាំពុទ្ធសាសនា។

ចុងបញ្ចប់ កម្លាំងរបស់ពុទ្ធសាសនា ត្រូវប្រែក្លាយទៅជាកម្លាំងរបស់បក្សកុម្មុយ-និស្តកម្ពុជា។ គ្មាននរណាម្នាក់ហ៊ានថ្លែងពាក្យ "ពៀរមែនរំងាប់ ដោយការមិនចងពៀរ" ទៀតទេ។ ម្នាក់ៗ ធ្វើការតាមផែនការ ដែលដាក់ចុះ ដូចជា រំលំបំផ្លាញ "កំហឹងវណ្ណៈ ឲ្យឆាបឆេះ ជានិច្ចចំពោះខ្មាំង" តាមគោលជំហរ សីលធម៌បដិវត្តន៍។

កម្លាំងរបស់បក្សកុម្មុយនីស កម្ពុជា ត្រូវតែជាឧបករណ៍ដ៏បរិសុទ្ធ ក្នុងអត្ថជ័យ ទាំងពីរយ៉ាង ខាងលើនេះដែរ។

កាំង ហ្គេកអ៊ាវ

"ស៊ីលធម៌បដិវត្ត" ជាឯកសារខ្លី សាមញ្ញ តែអស់ជីវិត ។

## III.– អំពីវត្តអារាម និងសម្បត្តិពុទ្ធភ័ណ្ឌ

វត្តអារាមទាំងអស់ នៅតំបន់រំដោះ ចាប់ផ្តើមខូចខាត សម្បត្តិពុទ្ធភ័ណ្ឌចាប់ផ្តើម បាត់បង់ តាំងតែពីពេល ដែលអស់លោកសង្ឃ ។

ក្រោយ 17 មេសា 1975

- នៅជនបទ វិហារសាលាឆាន់ណាក៏ដោយ ក៏គេវាយយកដែកឈើទំរប់ ។
- នៅភ្នំពេញ

–. សម្បត្តិពុទ្ធភ័ណ្ឌ ត្រូវគេបោះយកទៅចោល ។

–. មានវិហារពីរ ដែលប៉ុលពត គ្រោងកំទេចចោល ដោយវិធីបំបែងជាង ៖

មួយ.– វិហារវត្ត សារាវ័ន្តតេជោ ជាវិហារបុរាណ – ប៉ុលពត បានបញ្ជាឲ្យ ដាំឡៀបខ្សែដែក មួយឲ្យជិតក្នុងវត្តនេះ ថ្ងៃក្រោយគង់តែកម្មករ កំទេចវិហារ ។

ពីរ.– ចេតិយ និងវិហារវត្តភ្នំ ដែលជានិមិត្តរូបក្រុងភ្នំពេញ ត្រូវបាន ប៉ុលពត គ្រោងវាយចោល ដោយសង់វិមានអំបុក (693 ERN 00 003 137–138) ជំនួសវិញ ។

សម្គាល់៖ ពេលអ្នកតាឃ្លាំងមឿង ដែលជាអ្នកតាដែលក្បាលបងទប់ព្រះមហាក្សត្រ ក៏ត្រូវ បានគេវាយចោលដែរ បន្ទាប់ពី 17 មេសាបន្តិច ។ នាងបច្ចុប្បន្ន ជាសំណង់ថ្មី ។ ពេលនេះ ជាប់គាំងនឹងជំនឿបុរាណ ។

## IV.– កំទេចលោកចាស់ កសាងលោកថ្មី

នេះ ជាគោលស្លោកធំបំផុតរបស់ "បដិវត្តន៍វប្បធម៌" – ប៉ុលពត យកមក អនុវត្ត យ៉ាងសកម្ម តែយ៉ាងស្ងៀមស្ងាត់ ។

### ក.– បោះបង់វត្តអារាម បង្កើតសហករណ៍

វត្តជាមូលដ្ឋានរបស់ពុទ្ធសាសនា សហករណ៍ជាមូលដ្ឋាននៃកុម្មុយនិស្ត ។

- សហគមន៍ស្រួច និងក្រុមប្រវាស់ដៃ ជាពន្លកនៃសហករណ៍
- ឆ្នាំ 1972 ចាត់តាំងសហករណ៍ជាពិសោធន៍ នៅខេត្តព្រះវិហារ
- ឆ្នាំ 1973 ចាត់តាំងសហករណ៍កំរិតខ្ពស់នៅតំបន់រំដោះ
- ឆ្នាំ 1975 ថ្ងៃ 20 ឧសភា សំរេចពង្រីកវិសាលភាព សហករណ៍កំរិតខ្ពស់ ឲ្យគ្របដណ្តប់ពេញផ្ទៃប្រទេស
- ឆ្នាំ 1978 ជំរុញមួយជំហាន ថែមទៀត ឲ្យទៅជាសហករណ៍ដើរទៅស្ទើរ ។

កាំង ហ្គេកអ៊ាវ

ខ.- ធ្វើមិទ្ទិញភូមិ ជំនួសពិធីបុណ្យប្រពៃណី

នៅមូលដ្ឋានបង្អែក ពិធីបុណ្យប្រពៃណី លាយបាត់អស់ ចាប់តាំងតែពីឆ្នាំ 1971។ មិទ្ទិញភូមិ ត្រូវបានបង្ហាត់ ឲ្យធ្វើជាបន្តបន្ទាប់ - មិទ្ទិញលើកណាក៏ដោយ ក៏តែងតែបញ្ចប់ ដោយចំរៀង "ណែវើយ អាត្មាញញៃប្រ"។

គ.- ជ័យគុណមហាបិតា គ្រូ បា អាចារ្យ នឹងសក្ដិភូមិ

មុន17 មេសា គេប្រើវិធីបណ្ណាយចិត្ត ដោយមិនជំហ៊ាយឲ្យថប់។ ក្រោយ 17 មេសា ទើបគេចេញចំរៀងមួយបទ "ឪពុក ម្ដាយ បង្កើតបានមនុស្ស តែម្នាក់ អង្គការ បដិវត្ត វិញ ដោះ បាន មនុស្ស មួយនគរ។" 

ឪពុក ម្ដាយ ដែលចែកស្លាកជា បក្សយកលេសអញ្ចោះ យកលេសអញ្ចុះ ទប់ទល់ មិនឲ្យធ្វើពិធីបញ្ចុះសព ឲ្យបានសមរម្យជាមនុស្ស នោះតែម្ដង។

"ញ៉ាំកពោតដំកំប៉ុង ដាល់ក្បាលក្លួចដាក់ទឹកបាន"។

ក្នុងការលុបបំបាត់ពុទ្ធសាសនានេះ ប៉ុលពតបានក្លែងបន្លំប្រវត្តិសាស្ត្រ ដូចជា៖

• មាត្រា20 នៃរដ្ឋធម្មនុញ្ញ សរសេរបំភ័ន្តថា "ប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិ មិនមានជំនឿអ្វី ឬមិនជឿ សាសនាណាក៏បាន"

• គេះបំផ្លិចលោកសង្ឃអស់សេីង វត្តអារាម ត្រូវបានរំលាយចោលបណ្ដើរៗ ក៏ ប៉ុល ពត នៅតែវិលាក់បំពាំងការពិត។ នៅក្នុង សេចក្តីថ្លែងការណ៍ផ្ទៃក្នុងបក្ស ថ្ងៃ27 កញ្ញា 1977 ប៉ុល ពត នៅតែបន្ត លើកតម្កើង ព្រះបរមរាម "ជនណាត"

• ពាក្យដែលប៉ុលពត និយាយប្រាប់ខៀមនថា៖ "បំបាត់ពុទ្ធសាសនា ជាចលនាមហាជន..." ជាពាក្យបំភ្លៃ និយាយយកប្រៀប ពីព្រោះ តាមការពិត គ្មានក្រុមៗណា ទៅបបួលលោកសង្ឃឲ្យសឹកចូលធ្វើចឹតា ដូចប៉ុលពត កុហក់ខៀមនទេ។

## V.- អំពីសាសនាប្រតិកិរិយា

លក្ខន្តិកៈបក្សគ្រប់ជំនាន់ (60, 71, 76) កំណត់យកការប្រឆាំងគតិនិយម ទុកជា គោលដៅរបស់ខ្លួន។

ក្រោយ 17 មេសា 1975 មានឯកសារពីរបន្ថែមទៀត៖

មួយ.- រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា20 សរសេរថា "មិន អនុញ្ញាត ឲ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញ កម្ពុជាប្រជាធិបតេយ្យ និងប្រជាជន កម្ពុជា ជាដាច់ខាត (ERN 00 089 851)

ពីរ.- សេចក្ដីសំរេចថ្ងៃ 30 មីនា 1976 ឲ្យកំទេច សាសនវិហារកាតូលិក-កំទេច នៅឆ្នាំ 1977 ។

សរុបមក សាសនាប្រតិកិរិយា តាមការពិត គឺតជាសំដៅគ្រីស្តសាសនា។



កាំង ហ្គេកអាវ

## VI.– អំពីអ៊ីស្លាម និងចាម

ស្រុកខ្មែរយើង យល់ដឹងអំពីអ៊ីស្លាម តិចតួចណាស់។ ចាម មានជោគវាសនាលិចអណ្តែត ទៅតាមគោលនយោបាយរបស់បក្ស៖

- ពីឆ្នាំ 1945 ដល់ 1954 – បក្សមានគោលនយោបាយប្រមូលកម្លាំងចាម
- ពីឆ្នាំ 1954 ដល់ 1970 – បក្សទុកចាមចោល
- ពីឆ្នាំ 1970 ដល់ 1975 – បក្សទុកចាមចោលដដែល
- ក្រោយ 17 មេសា 1975 – បក្សចាប់ផ្ដើមលុបបំបាត់អ៊ីស្លាម។

2] និងចាត់ការតៃយកមូស្លីម ទៅពង្រាយក្នុងចំណោមខ្មែរ - រកណាមើលក៏ទេ។

សារលេខ 15 ចុះថ្ងៃ 30 វិច្ឆិកា 1975 ជាភស្តុតាងបញ្ជាក់ថា ប៉ុលពតខ្លួនជាក្នុងនាម បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាឲ្យជំលៀសប្រជាជនបូព៌ា ក្នុងនោះមានមូស្លីម 1 សែន 5 ម៉ឺននាក់ ពីតាមដងទន្លេ និង ពីតាមបណ្ដោយព្រំដែន យកទៅឧត្តរ និង ពាយ័ព្យ (LN 0 001 045 – 01 UUR – ERN 00 008 494)។

## VII.– លុបបំបាត់សាសនា ជាការងារ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ

ដើម្បីសំរេចយុទ្ធសាស្ត្រនេះ បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តតាមយេការយុទ្ធវិធី ដូចខាងក្រោម៖

- ពីឆ្នាំ 1956 ដល់ឆ្នាំ 1970 – ប្រលេះយកកម្លាំងពីពុទ្ធសាសនា ទុកសាសនាផ្សេងទៀត ចោលមួយឡែក។
- ក្នុងតំបន់រំដោះ ពីឆ្នាំ 1970 ដល់ឆ្នាំ 1975 – បន្តប្រលេះយកកម្លាំងពីពុទ្ធសាសនាយ៉ាងសកម្ម និងបណ្ដោយចិត្ត មិនឲ្យប្រជាជន ទំនុកចិត្តដល់គុណធម៌អ្វីទាំងអស់។
- ពីថ្ងៃ 17 មេសា 1975 តទៅ ទើបវាយផ្ដាច់ សាសនានិងជំនឿទាំងអស់ ដើម្បីបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯង ឡើងជាម្ចាស់ លើចិត្តគំនិតមនុស្ស ទៅតាមគោលដឹកនាំ វណ្ណៈ ដែលមានដែរជាសន្ទេប ក្នុងសីលធម៌បដិវត្ត ដោយប្រើប្រាសបន្ទំបំភ្លឺ បំផុសគំនុំសង្សឹក បង្អនុវត្តក៏ទេច។

របបផ្ដាច់ការទាំងអស់ មិនខុសគ្នាប៉ុន្មានទេ។

## VIII.– គុណធម៌របស់សាសនាទាំងបួន



សេចក្ដីពិត សេចក្ដីស្រឡាញ់ និងសេចក្ដីសន្ដោស ដែលជាគុណធម៌ដ៏ថៃថ្លៃ សាសនាទាំងបួន គឺពុទ្ធសាសនា គ្រីស្តសាសនា អ៊ីស្លាម និងខុងជឺនិយម មានអានុភាពគ្មានដែនកំណត់។

កាំង ហ្គេកអាវ

00787970

សូមជូនឧទាហរណ៍ពីរ៖

មួយ.– នៅក្នុងសំណុំរឿងលេខ 001 មន្ត្រីមេហ៊ាយម្នាក់ ឈ្មោះ ឌុច បានចូលមក ធ្វើសក្ខីកម្ម។ មនុស្សទាំងអស់ ដែលបានស្តាប់ សុទ្ធតែជឿថា នេះជាសម្លេងនៃសេចក្តីពិត។

ពាក្យពិត ញ៉ាំងឲ្យពាក្យភូតភរ សាបសោប។

ពីរ.– កាលពីថ្ងៃ 26 កក្កដា 2010 ជនដីខ្មែរម្នាក់ បានឲ្យសម្ភាស ដល់វិទ្យុបារាំងអន្តរជាតិថា៖ "ទៀតមែនតែជាប់ ទោះយកាមិនចេញទៀត"។

នេះជាសម្លេងនៃសេចក្តីសង្គ្រោះ ដែល ចំពោះមុខ បានផ្សារភ្ជាប់មហាចិត្តជាក់លាក់។

ប្រជាជនសាមញ្ញ ទាំងពីររូបនេះ អាចធ្វើការអស្ចារ្យបាន មកពីក្នុងខ្លួនចិត្តគាត់ មានសក្តានុពលអាចកំចាត់ ចំនួនខ្ពស់បំផុតមួយ។

សង្កេត៖ អ្នកនយោបាយ សតវត្សទី20 លើងនេះ មានពីររូប គឺ តឹង សៀវភីង (1904–1997) និង Nelson MANDELA (1918 .....) ដែលបានយកគុណធម៌ ហង្សសើមកប្រតិបត្តិ។

គុណធម៌ទាំងបីនេះ អាចជាគ្រឹះដ៏រឹងមាំបំផុត សំរាប់ឲ្យមនុស្ស ចងក្រងសាសនាទាំងបួន ឲ្យមូលត្រកូលគា ដើម្បីមានសក្តានុពលប្រមូលផ្តុំ អំណោយផល បង្រួបបង្រួមជាតិ និងផ្សះផ្សាជាតិ។

13.



តាំង ហ្វេកអ៊ាច

00787971

## ជំពូកបួន

## ស្វែងយល់អំពីការងាររបស់អនុលេខាបក្ស នួន ជា

4

### I.- ទ្រឹស្តីការងារ នៃការងារនគរបាលរបស់បក្ស

ក្នុងសម័យសង្គ្រាម នគរបាលបង្កើតឡើង ដើម្បីស្វែងរកខ្មាំង និងកំទេចខ្មាំង។ ឲ្យតែចូលតំបន់នោះ ក៏ត្រូវសន្មតថាជាខ្មាំង ដែលត្រូវតែកំទេច។ នេះជាគោលនយោបាយ របស់បក្ស។

ដោយឃើញខ្ញុំស្ទាក់ស្ទើរ ចាំឲ្យមានបក្ខភាព វ័យតុក នៅឆ្នាំ1973 អ៊ុង ហឿន បានណែនាំថា ជាមួយខ្មាំង ត្រូវតែដាច់ខាត កុំឲ្យបាត់បង់ដៃនោះ ម្តងមួយដុំៗ ដូចក្នុងសម័យគន្លឹះទៀត គឺសម័យតស៊ូ។

ក្រោយកំណើតរដ្ឋអំណាច កម្ពុជាប្រជាធិបតេយ្យ នគរបាលសម័យសង្គ្រាម ត្រូវណាស់ តែត្រូវបានកែប្រែ ឲ្យដូចប្រទេសគេឯងឡើង។

សង្កេត៖

—.ឆ្នាំ 1967 ខ្ញុំបានទស្សនា ខ្សែភាពយន្តប្រតិចារកម្មចិន។ ខ្ញុំសង្កេតឃើញថា វិធី ដែលគេប្រើ ក្នុងការតាមដានស្រាវជ្រាវ មានលក្ខណៈវិទ្យាសាស្ត្រ របស់គេ។

—.ឆ្នាំ 1977 ប៉ុល ពត ទៅទស្សនកិច្ចនៅចិន មួយខែ - បីថ្ងៃ ជាទស្សនកិច្ចផ្លូវការ។ ប៉ង់ ដែលជាអ្នកដូនដំណើរ ប៉ុល ពត បានតំណាលប្រាប់ខ្ញុំថា ចិនរៀបការយ៉ាងល្អណាស់ មុននឹងសំរេចចាប់បានបុគ្គលម្នាក់ គេតែរកឃើញកត្តាប ៤៥ ចំណោទរឿង មានលក្ខណៈជាប្រព័ន្ធ។

បច្ចេកវិទ្យា នគរបាលប្រតិចារកម្មចិន បានបោះជំហានទៅឆ្ងាយហើយ។

ផ្ទុយទៅវិញ បក្សកុម្មុយនីស្តកម្ពុជា នៅតែក្រញាំដៃដាច់ខាតចាស់ និងបច្ចេកទេស តាំងតែពីសម័យតស៊ូ។ ក្នុងការប្រតិបត្តិ សុនសេន តែងតែណែនាំថា "កុំបច្ចេកទេស"។ ចុងបញ្ចប់ ក្រោយទស្សនកិច្ចរបស់ ប៉ុល ពត នៅចិន សុនសេន បានណែនាំស21

កាំង ហ្គេកអ៊ាវ

00787972

ខ្លឹមសារអំពីខ្មែរក្រហម៖ អត្ថបទដែលប៉ុនសារ៉េម ត្រូវបានចុះលេខ E5.2.25 ។

## II.– អំពីការងារបក្ស

ថ្ងៃ 9 តុលា 1975 ប៉ុលពត បានបញ្ជាក់ថា អនុសេនាធំ ដួច ដា ទទួលការងារបក្ស – ក្នុងបក្សកុម្មុយនីស្តកម្ពុជា (D00 677 ERN 00 019 108) ។

ការងារបក្សគឺ៖

មួយ.– បញ្ចូលបក្សថ្មី ដោយឈរលើលក្ខណៈប្រវត្តិរូបល្អ ជាប់ជាប់ខ្លួន ឈរលើវណ្ណៈភាពល្អ និងឈរលើប្រវត្តិរូបច្បាស់លាស់ (លក្ខន្តិកៈបក្ស D00674 ERN 00 053 013–016) ។ ២

ពីរ.– ជំរៀបថ្នាក់កម្មាភិបាល ដោយឈរលើលក្ខណៈសម្បត្តិ 10 យ៉ាង (D00 674 ERN 00 053 020–023) – ក្នុងនេះ ទី7 និងទី8 បញ្ជាក់ថា បក្សយកចិត្តទុកដាក់ ដល់ជីវទស្សនៈបរិសុទ្ធ និងប្រវត្តិរូបបរិសុទ្ធ ទី1 ដល់ទី4 បញ្ជាក់ថា បក្សយកចិត្តទុកដាក់ជាពិសេស ដល់ប្រវត្តិកម្មភាព

បី.– អនុវត្តវិន័យ ចំពោះបក្ខជនណាដែលប្រឆាំងមាគ៌ានយោបាយរបស់បក្ស គោលជំហរសតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំង និងលក្ខន្តិកៈរបស់បក្ស (D00674 ERN 00 053 018–019) – ការងារនេះតម្រូវឲ្យក្ដាប់ប្រវត្តិកម្មភាព ។

ដោយឡែក នៅក្នុងកងទ័ពមជ្ឈឹម ដែលទើបចាត់តាំងក្នុងខែកក្កដា 1975 ក៏ ប៉ុលពត បានកំណត់ក្នុងឯកសារថ្ងៃ 9 តុលា 1975 ឲ្យសុនសេន ទទួលការអប់រំនយោបាយ ចំណែកអនុសេនាធំ ដួច ដា គឺក្ដាប់ប្រវត្តិរូប និងជីវទស្សនៈ តាមរយៈកម្មាភិបាលទទួលការងារប្រវត្តិរូប និងជីវទស្សនៈ (D00 677 ERN 00 019 120) ។

សរុបមក ការងារបក្ស តម្រូវឲ្យអនុសេនាធំ ដួច ដា ដែលជាអនុសេនាធំ តាំងតែពីឆ្នាំ 1960 ក្ដាប់ប្រវត្តិរូបបរិសុទ្ធ ជីវទស្សនៈបរិសុទ្ធ និងប្រវត្តិកម្មភាពបរិសុទ្ធ របស់កម្មាភិបាលបក្ស ឲ្យបានច្បាស់លាស់ ជាបន្តបន្ទាប់ ។ តាមរយៈការងារនេះ គាត់បានណាក្ដាប់ប្រវត្តិរូប ជីវទស្សនៈ និងប្រវត្តិកម្មភាពរបស់កម្មាភិបាលបក្សថ្នាក់ក្រោម បានច្បាស់លាស់ជាងខ្លួន ដាទេ ។

## III.– អំពីការងារនគរបាលរបស់បក្ស

តាមការងារសំខាន់ក្នុងបក្ស ប៉ុលពតបានសរសេរ នៅថ្ងៃ 9 តុលា 1975 ថា មិនយកចម្លើយទាំងអស់ទុកជាមូលដ្ឋានទេ (D00677 ERN 00 019 122) ។ គាត់លើកហេតុផលថា៖ "ពីព្រោះវាឆ្លើយបត់បែន ។ គេប្រវត្តិតាមខ្សែរយៈក្រោមបើជាង – ធ្វើតាមទាំងមិនបានទេ ។" ការវិនិច្ឆ័យពិតប្រាកដមិនពិត គឺតាមខ្សែយើង ។

ខ្សែយើង គឺខ្លួនដា ។



កាំង ហ្គេកអ៊ាវ

00787973

ឯកសារថ្ងៃ ៩ តុលា 1975 (D00 677 ERN 00 019108) បានចាត់តាំងសុនសេន ឱ្យទទួលយកសន្តិសុខ។

មន្ទីរនគរបាលកងអស់ មាន 196 ក្រៅពី ស.21។ មន្ទីរនគរបាលកងអស់ ធ្វើចម្លើយសារភាពជូនថ្នាក់លើ។ មានចម្លើយសារភាពបី ដែលមិនមែនជារបស់ ស.21 ដែលតុលាការបានបញ្ចេញយកមកឱ្យខ្ញុំពន្យល់ គឺ៖

D58/II មកពីភូមិភាគបូព៌ា

E52/4.62 មកពីភូមិភាគនិរតី

D32/IV ឬហៅថា D42/IV មកពីភាគឧត្តរថ្មី។

សង្កេត៖ ចម្លើយសារភាពទាំងបីនេះ គ្មានចំណារសុនសេនទេ ដោយឡែក D32/IV មានលិខិតអមផ្ញើរបស់កងចាប លេខាឧត្តរថ្មី ចុះថ្ងៃ 17.4.78 និងមានចំណារ នួន ជា ចុះថ្ងៃ 19.4.78 បញ្ជាឱ្យតាមដានទាំងអស់។

ចំណែកចម្លើយ ដែលផ្ញើចេញពី ស.21 ដែលតុលាការបានផ្តល់ឱ្យខ្ញុំពន្យល់ មាន E3/20 D93/III និង E3/416 ដែលសុនសេនចារជូនប៉ុលពតផ្ទាល់ និង E3/86 ដែលសុនសេន ចារជូន នួន ជា ផ្ទាល់ ពីព្រោះពេលនោះប៉ុលពតសំរាក។ នួន ជា បានអាន ហើយកត់ចារ បញ្ជាទៅតំបន់ 33 និង 35 ផង។

ត្រួតកាលបរិច្ឆេទខ្លះ៖

ថ្ងៃ 15.8.77 សុនសេន ឈប់ដឹកនាំ ស.21 ផ្ទាល់

ថ្ងៃ 25.11.77 ជាថ្ងៃចុងក្រោយ ដែលមានចំណារ សុនសេន នៅលើចម្លើយរបស់ ស.21។

កាលបរិច្ឆេទទាំងនេះ អាចឱ្យសន្និដ្ឋានបានថា សុនសេនទទួលភារកិច្ច ស្របចម្លើយ ជួសអង្គការបក្ស ហេតុដល់ថ្ងៃ 25.11.77 ដល់ថ្ងៃ 26.11.77 ទើបមក នួន ជា ទទួល ភារកិច្ចផ្ទាល់ និងផ្ទាល់មុខ ក្នុងការមន្ទីរនគរបាលបក្ស - ចំណារ នួន ជា ដែលមាន គឺជា សេចក្តីសំរេច។

ការងារនគរបាលរបស់បក្ស ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ដែររបស់បក្ស គឺរបស់ លេខាបក្ស និង អនុលេខាបក្ស ដែលជាដៃគូ ផ្ទាល់មុខ និងគណៈអចិន្ត្រៃយ៍ (លក្ខន្តិកៈបក្ស D00 674 ERN 00 053 009)។

សុនសេន ចាត់តាំងខ្ញុំ ដើម្បីកំណត់បន្ទុក លេខា និងអនុលេខាបក្ស (D00 677 ERN 00 019109)។

សង្កេត៖

D93/III ដែលប៉ុលពត បញ្ជាឱ្យសុនសេនទាក់ទងខាងបូព៌ា ជាភស្តុតាងសំរាប់ បញ្ជាក់អំណាចអំណាចនេះ។

## IV. - អំពីគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស



កាំង ហ្កេកអ៊ាវ

00787974

លក្ខន្តិកៈបក្ស ជំពូក VI មាត្រា 27 (D00 674 ERN 00 053 035) សរសេរថា "កងទ័ពបដិវត្តន៍កម្ពុជា គឺមិនប្រភេទ ស្រុក តំបន់ ឈប ត្រូវស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ ដាច់ខាត និងត្រឹមត្រូវ របស់បក្សកុម្មុយនិស្តកម្ពុជា"។

តាមប្រវត្តិរបស់វា កងទ័ពស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្ស គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខា និងអនុលេខាបក្ស៖

-. ឆ្នាំ1958 ភូមិភាគនីមួយៗ ចាប់ផ្តើមកសាងកងឈ្លប តាមការណែនាំ និងក្រោមការដឹកនាំរបស់បក្ស។

-. ឆ្នាំ1974 ក្រោមការដឹកនាំរបស់បក្ស ភូមិភាគនីមួយៗប្រមូលផ្តុំកងទ័ពបានជាកងពល និងចាប់ផ្តើមវាយរំដោះភ្នំពេញ នៅខែមករា 1975។ ២

-. ខែកក្កដា 1975 បក្សបានយកកងទ័ព ពីភូមិភាគសំខាន់ៗ មួយភូមិភាគ ពី ពីរ-បីកងពល យកមកបង្កើតជាកងទ័ពមជ្ឈិម ឬហៅថា កងទ័ពស្រួច។

លក្ខន្តិកៈបក្ស ឆ្នាំ1976 កំណត់ថា៖

-. កងឈ្លប ស្ថិតនៅក្រោមការចុះដាក់ និងបញ្ជាផ្ទាល់របស់គណៈកម្មាធិការបក្សស្រុក (មាត្រា 13)

-. កងតំបន់ ស្ថិតនៅក្រោមការចុះដាក់ និងបញ្ជាផ្ទាល់របស់តំបន់ និងភូមិភាគ (មាត្រា16 និងមាត្រា19)

-. កងទ័ពស្រួច ស្ថិតនៅក្រោមការចុះដាក់ និងបញ្ជាផ្ទាល់របស់លេខាធិការ (D677 ERN 00 019 108 ដល់ ERN 00 019 120)

មាត្រា 27 ជំពូក VI នៃលក្ខន្តិកៈបក្ស សរុបទាំងអស់ឲ្យមកស្ថិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត នួន ជា - នួន ជា ដែលជាអនុលេខាបក្ស ចាប់តាំងពីខែតុលា 1960។

គណៈកម្មាធិការយោធាមជ្ឈិមរបស់បក្ស គឺ ប៉ុល ពត នួន ជា [illegible] ស៊ុន សេន និង កែ ពក។

## V.- តួនាទីរបស់អនុលេខាបក្ស នួន ជា

ក.- គ្រប់ការងារទាំងអស់ ប៉ុល ពត លេខា ជាអ្នកសម្រេច នួន ជា អនុលេខា ជាអ្នកតាមដានការអនុវត្ត។ គោលការណ៍នេះ ស្ថិតនៅជាធរមានរហូតមកហើយ។ ERN 00 019 109 នៃ D00677 គ្រាន់តែជាការរំលឹក។

សារលេខ15 ចុះថ្ងៃទី 30.11.75 ជាភស្តុតាងមួយ។ សារនេះ លោកតា ផ្ញើមកប៉ុល ពត ហើយចម្លងជូន នួន ជា ដើម្បីមេត្តាណែនាំដោះស្រាយ។



កាំង ហ្គេកអ៊ាវ

ខ.- គ្រប់ការងារ បើប៉ុល ពត មិនទៅ នួន ជា សំរេចសេចក្តីក្នុងនាមបក្ស (D00677 ERN 00 019 112)។

ដោយឡែក ខាង ការងារសំរាកសំរាង សូមលើកភស្តុតាងពីរ៖

មួយ.- E3/86 នួន ជា សំរេច តាមសេចក្តីរាយការណ៍របស់ សុខសេន

ពីរ.- D32/III នួន ជា សំរេច តាមសេចក្តីរាយការណ៍របស់ កង ចាប ។

បញ្ជាក់៖ សភាតំណាងប្រជាជនកម្ពុជា ជាស្ថាប័នរូបគំនូ មានតែឈ្មោះ អត់អង្គភាព អត់សកម្មភាព។ តំណាងទាំងអស់ ចិតនៅជាមួយប្រជាជនរបស់ខ្លួន តទៅ

3 ទៀត (693 ERN 00 003 141)។

## V.- ប៉ុលពត ជាម្ចាស់នៃមាគ៌ាបក្ស

នៅក្នុងវគ្គសិក្សាឆ្នាំ 1978 ប៉ុលពតរៀបរាប់ថា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា អ្នកធ្វើ គឺជាអ្នកចងក្រងមាគ៌ា។ ធ្វើមាគ៌ា គឺដើម្បីដឹកនាំចលនា ដឹកនាំការងារ។

ពាក្យចំណាំនេះ មកពីសារៈបញ្ញាប្រវត្តិបក្ស ដែលបានធ្លាប់ថា អញ្ចឹងមែន។

ជាច្រើនឆ្នាំ ចាប់តាំងតែពីឆ្នាំ 1971 មក ហេងរិនមកជុំគា- ចាប់ផ្តើមរៀបចំវគ្គ -គណៈកម្មាធិការភូមិភាគ ត្រូវរៀនសៀវភៅ ជាមួយប៉ុល ពត យេវេលាប្រហែលកន្លះខែ។ ត្រឡប់មកថបវិញ ក៏ចែកគ្នា ធ្វើការតាមៗ មាន បើកវគ្គអប់រំនយោបាយឱ្យ កម្មាភិបាលខាងក្រោម បើកវគ្គវាយសិក្សាសមាភូមិក្រោយ វាយសិក្សាត្រៀមរៀបចំសមា-ភូមិមុខ តាមមាគ៌ាថ្មី ទស្សនៈសភាពការណ៍ថ្មី ទិសវាយសិក្សាថ្មី របស់បក្ស។

នៅមូលដ្ឋាន អ្នកទទួលខុសត្រូវអប់រំនយោបាយ គឺលេខាភាគ - អប់រំមិនសើស ពាក់កន្លះខែ 15 ក្នុងមួយឆ្នាំ។

នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ប៉ុលពត ជាម្ចាស់នៃមាគ៌ាបក្ស។ គាត់កាន់កាប់សិទ្ធិផ្តាច់មុខ ក្នុងការយកលទ្ធិម៉ាក្ស ឡេនីន មកអនុវត្តឱ្យរស់រវើក តាមសភាពការណ៍ជាក់ស្តែងនៃកម្ពុជា (លក្ខន្តិកៈបក្ស D00674 ERN 00 053 010 កថាខណ្ឌ ទី4)។

កាំង ហ្គេកអ៊ាវ

# សរុបបញ្ចប់

តាមរយៈប្រវត្តិសាស្ត្រ នៅកម្ពុជា កន្លងមកនេះ បង្ហាញឲ្យឃើញថា៖

មួយ.- លន់ណុល ធ្វើរដ្ឋប្រហារទម្លាក់សីហនុ ធ្វើសង្គ្រាមចាញ់ប៉ុលពត ដោយសារតែ លន់ណុលគាត់ប្រឆាំងប្រជាជនក្រៅ តាំង។ 3

ពីរ.- ប៉ុលពតឈ្នះលន់ណុល ដោយសារតែ ប៉ុលពត នេះប្រើក្រោមម្លប់ បង្រួបបង្រួមជាតិ និងនេះដែរ កម្លាំងសីហនុដែលមក ឲ្យមកជាកម្លាំងបដិវត្ត។

បី.- ប៉ុលពត ចាញ់សង្គ្រាមវៀតណាម ដោយសារតែប៉ុលពត បំផ្លាញកម្លាំងរបស់ខ្លួនឯង និងដោយសារតែ យកសង្គ្រាមជាមធ្យោបាយ ដោះស្រាយទំនាស់។

បួន.- ប៉ុលពត បរាជ័យ ក្រោមស្នាដៃ ហ៊ុនសែន មកពីប៉ុលពត លើកគោលនយោបាយ ខុសឆ្គង ក្នុងការចងក្រងកម្លាំង។

ប្រាំ.- សីហនុ ជាបិតាបង្រួបបង្រួមជាតិ ដែលខ្មែរយើង ចងចាំក្នុងនាទីគុណ តែបង្រួបបង្រួមជាតិនេះ មានចន្លោះប្រហោង ទើបលន់ណុល បន្ទាប់មកគឺប៉ុលពតធ្វើរដ្ឋប្រហារបាន។

ផ្លូវដើរមានពីរ ទីមួយគឺផ្លូវបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ទីពីរ គឺផ្លូវ ដណ្តើមកម្លាំង ប្រហើយ វាយផ្តាច់តែឯង។

លក្ខណៈទី២នេះ សំរាប់កំណត់មាត់ត្រឹមត្រូវ ប្រហែលជាអាច ស្ថិតស្ថេរភាព ប្រទេសជាតិ ជីវភាពប្រជាជនកាន់តែល្អប្រសើរ ផលិតផលសរុបក្នុងស្រុក កាន់តែកើន ឡើង។

សាសនាពិបអស់ ជាកម្លាំងរបស់ជាតិ មានតែបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ទេ ទើបមានសុខុមៈ គឺជាណាអំពីការចងក្រង សាសនាឲ្យមូលត្រកូលគ្នា។

ចប់

កាំង ហ្គេកអ៊ាវ

## តារាងរាយឈ្មោះអត្ថបទ


| | | |
|---|---|---|
| សំនាំដើម | | ទំព័រ 1 |
| ជំពូកមួយ | សង្ខេបប្រវត្តិកម្ពុជា តាមការស្រាវជ្រាវផ្ទាល់ | ទំព័រ 4 |
| ជំពូកពីរ | ស្វែងយល់មាគ៌ាសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា | ទំព័រ 21 |
| ជំពូកបី | អំពីសាសនានិងជំនឿក្នុងរបបប៉ុលពត | ទំព័រ 28 |
| ជំពូកបួន | ស្វែងយល់អំពីការងាររបស់អនុលេខាបក្ស នួន ជា | ទំព័រ 34 |
| សរុបបញ្ចប់ | | ទំព័រ 39 |




កាំង ហ្គេកអ៊ាវ